SEIU 775
BENEFITS GROUP



Dora P.
អ្នកថែទាំ, Tacoma

# មគ្គុទេសក៍អត្ថប្រយោជន៍សុខភាព

## OPEN ENROLLMENT (ការបើកទទួលចុះឈ្មោះ) ឆ្នាំ 2024

ធ្វើការផ្លាស់ប្តូរ ឬប្តូរការធានារ៉ាប់រងរបស់អ្នកត្រឹមថ្ងៃទី 20 ខែកក្កដា។

**ត្រូវការជំនួយ? ហៅទូរសព្ទទៅលេខ 1-877-606-6705**

Ver en español: myseiu.be/oe-es
查看中文版 : myseiu.be/oe-zh
한국어로 보기: myseiu.be/oe-ko
Посмотреть на русском: myseiu.be/oe-ru
Переглянути укр: myseiu.be/oe-ua
Xem bằng Tiếng Việt: myseiu.be/oe-vi
Ku eeg Af-Soomaali: myseiu.be/oe-so
ਪੰਜਾਬੀ ਵਿੱਚ ਪੜ੍ਹੋ: myseiu.be/oe-pa
អានជាភាសាខ្មែរ: myseiu.be/oe-kh
myseiu.be/oe-ar: عرض باللغة العربية

**myseiu.be/oe**

ជូនចំពោះអ្នកថែទាំជាទីគោរព,

ខ្ញុំចូលចិត្តស្តាប់ពីរបៀបដែលការធានារ៉ាប់រងសុខភាពរបស់ SEIU 775 Benefits Group ពង្រឹងសុខភាព ពង្រឹងភាពស្ងប់ចិត្ត និងសន្តិសុខហិរញ្ញវត្ថុរបស់អ្នកថែទាំ។ នៅពេលអ្នកស្វែងយល់ពីអត្ថប្រយោជន៍សុខភាពរបស់អ្នក ខ្ញុំចង់ចែករំលែករឿងដែលបំផុសទឹកចិត្តមួយចំនួនរបស់ពួកគេ។

បន្ទាប់ពី Dani R. មកពី Asotin មានកូនទីពីរ គាត់បានចុះឈ្មោះកូនប្រុសដែលទើបនឹងកើត និងកូនបងរបស់គាត់នៅក្នុង Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) ដែលជាការធានារ៉ាប់រងបន្ថែមរបស់យើងសម្រាប់កូនរបស់អ្នកមើលថែ។ គាត់សរសើរ "អត្រាដ៏អស្ចារ្យរបស់យើងសម្រាប់ការថែទាំសុខភាពអ្នកនៅក្នុងបន្ទុក" ដែលអនុញ្ញាតឱ្យគ្រួសាររបស់គាត់សន្សំសំចៃបានកាន់តែច្រើនជារៀងរាល់ខែ។

ហើយ Deborah M. មកពីទីក្រុង Vancouver ថ្មីៗនេះត្រូវទទួលការវះកាត់បេះដូងចំហ។ ទោះបីចំណាយលើការវះកាត់សរុបរាប់សែនដុល្លារក៏ដោយ ប៉ុន្តែគាត់ចំណាយប្រាក់ចេញពីហោប៉ៅកាន់តែតិច។ ដោយមិនចាំបាច់ព្រួយបារម្ភអំពីការចំណាយ គាត់និយាយថា "ខ្ញុំអាចផ្តោតលើខ្លួនឯង និងការជាសះស្បើយរបស់ខ្ញុំ"។ ថ្ងៃនេះ Deborah ដកដង្ហើមបានស្រួលជាងមុនទាំងផ្លូវកាយ និងហិរញ្ញវត្ថុ។

---

**ខ្ញុំមានសេចក្តីរំភើបរីករាយក្នុងការចែករំលែកព័ត៌មានថ្មីៗអំពីការធានារ៉ាប់រងចុងក្រោយ រួមទាំងអត្ថប្រយោជន៍នៃការមានកូនដែលបានពង្រីកបន្ថែម អត្ថប្រយោជន៍បន្ថែមនៃការស្តាប់ ធ្មេញ និងភ្នែក រួមទាំងការចូលប្រើកម្មវិធីឥតគិតថ្លៃជាច្រើនទៀត។**

---

វាជាក្តីសង្ឃឹមរបស់ខ្ញុំដែលថាអ្នក - ដូចជា Dani និង Deborah ដែរ- នឹងទាញយកអត្ថប្រយោជន៍ច្រើនបំផុតពីការធានារ៉ាប់រងសុខភាពដែលអ្នកទទួលបានក្នុងនាមជាអ្នកថែទាំ។

សុខភាពរបស់អ្នកនៅ Good Health,



Merissa Clyde
នាយកប្រតិបត្តិ (CEO),
SEIU 775 Benefits Group

SEIU 775 BENEFITS GROUP


## 3 OPEN ENROLLMENT (ការបើកទទួលចុះឈ្មោះ) ឆ្នាំ 2024
ដាក់ពាក្យសុំ ឬធ្វើការផ្លាស់ប្តូរលើការធានារ៉ាប់រងសុខភាពរបស់អ្នក ត្រឹមថ្ងៃទី 1 – 20 ខែកក្កដា។

## 4 ការបង្កើនអត្ថប្រយោជន៍
ស្វែងយល់អំពីបច្ចុប្បន្នភាពនៃការធានារ៉ាប់រងចុងក្រោយបំផុត។

## 5 ទិដ្ឋភាពទូទៅនៃការធានារ៉ាប់រងសុខភាព
5 ជម្រើសនៃការធានារ៉ាប់រង និងការចំណាយ
6 សិទ្ធិទទួលបាន
6 ពេលណា និងរបៀបដាក់ពាក្យស្នើសុំការធានារ៉ាប់រង
7 របៀបរក្សាការធានារ៉ាប់រង

## 9 របៀបទទួលបាន Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)
ស្វែងយល់ពីជំហានដែលអ្នកត្រូវអនុវត្តដើម្បីទទួលបាន Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)។

## 10 គ្រប់គ្រងការថែទាំសុខភាពរបស់អ្នកតាមអ៊ីនធឺណិត
បង្កើតគណនីអនឡាញ ដើម្បីងាយស្រួលចូលប្រើការធានារ៉ាប់រង និងអត្ថប្រយោជន៍របស់អ្នក។

## 11 ព័ត៌មានសង្ខេបសំខាន់ៗនៃគម្រោងសុខភាព
11 អត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ
12 អត្ថប្រយោជន៍ឱសថតាមវេជ្ជបញ្ជា
12 អត្ថប្រយោជន៍សុខភាពផ្លូវចិត្ត និងសុខុមាលភាព
12 អត្ថប្រយោជន៍ភ្នែក
12 អត្ថប្រយោជន៍នៃការស្តាប់
13 សេចក្តីសង្ខេបអត្ថប្រយោជន៍ផែនការ

## 16 អត្ថប្រយោជន៍នៃការមានកូន និងការកសាងគ្រួសារ
ថ្មី!
ស្វែងយល់អំពីអត្ថប្រយោជន៍ថ្មីបំផុតរបស់អ្នក - ការមានកូន ការកសាងគ្រួសារ និងជំនួយពេលអស់រដូវ។

## 19 ជម្រើសនៃការធានារ៉ាប់រងសុខភាពធ្មេញ
20 Delta Dental
21 Willamette Dental

## 22 ធនធាន និងជំនួយគាំទ្រ

# Open Enrollment (ការបើកទទួលចុះឈ្មោះ) សម្រាប់ការធានារ៉ាប់រងលើការថែទាំសុខភាព

## ថ្ងៃទី 1-20 ខែកក្កដា

### ថ្ងៃទី 20 ខែកក្កដា គឺជាថ្ងៃផុតកំណត់របស់អ្នកដើម្បី៖

- ✓ ផ្លាស់ប្តូរគម្រោងសុខភាពធ្មេញរបស់អ្នក។
- ✓ ផ្លាស់ប្តូរគម្រោងសុខភាពរបស់អ្នក ដើម្បីទទួលបានអត្ថប្រយោជន៍ថ្មីៗ រួមទាំង Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) ផងដែរ។

¡គម្រោងសុខភាព KPWA POS គឺជាគម្រោងចាស់ឈប់ទទួលសមាជិក មានន័យថា គម្រោងនេះមិនអនុញ្ញាតឱ្យមនុស្សថ្មីចូលរួមទេ។ ប្រសិនបើអ្នកមិនចង់ធ្វើការផ្លាស់ប្តូរលើការធានារ៉ាប់រងរបស់អ្នកទេ អ្នកមិនចាំបាច់ចាត់វិធានការណាមួយឡើយ។

**¡មានសំណួរមែនទេ? ហៅទូរសព្ទទៅសេវាបម្រើអតិថិជនតាមរយៈលេខ 1-877-606-6705។**

**ការផ្លាស់ប្តូរ Open Enrollment (ការបើកទទួលចុះឈ្មោះ) នឹងមានប្រសិទ្ធភាព ថ្ងៃទី 1 ខែសីហា ឆ្នាំ 2024**

### ជារឿងងាយស្រួលក្នុងការប្តូរគម្រោងសុខភាពរបស់អ្នក ឬផ្លាស់ប្តូរគម្រោងធ្មេញរបស់អ្នកនៅ

**myseiu.be/oe-online**

ឬទូរសព្ទទៅ **1-877-606-6705** ដើម្បីប្តូរគម្រោង ហើយអ្នកនឹងទទួលបានមគ្គុទេសក៍អត្ថប្រយោជន៍សុខភាពថ្មី និងពាក្យស្នើសុំចុះឈ្មោះចូលរួមគម្រោងសុខភាពថ្មីរបស់អ្នក (ត្រូវបានចាត់តាំងអាស្រ័យលើលេខកូដតំបន់របស់អ្នក) ដោយមានការណែនាំអំពីរបៀបធ្វើការផ្លាស់ប្តូរ។



# ការបង្កើនអត្ថប្រយោជន៍ 2024

- ✓ ដែនកំណត់បរិក្ខារគាំហើញបានកើនឡើងរហូតដល់ $600 រៀងរាល់ 12 ខែ។
- ✓ ដែនកំណត់ឧបករណ៍ជំនួយការស្ដាប់បានកើនឡើងដល់ $3,000 សម្រាប់ត្រចៀកនីមួយៗ រៀងរាល់ 3 ឆ្នាំម្ដង។
- ✓ ដែនកំណត់រយៈពេលអត្ថប្រយោជន៍ប្រចាំឆ្នាំរបស់ Delta Dental និងដែនកំណត់អាយុកាលនៃការតម្រង់ធ្មេញបានកើនឡើងដល់ $5,000។
- ✓ ប្រាក់ចំណាយផ្ទាល់ខ្លួននៃការតម្រង់ធ្មេញ Willamette Dental បានកាត់បន្ថយមកត្រឹម $1,500។
- ✓ បរិក្ខារជំងឺទឹកនោមផ្អែម និងបរិក្ខារវេជ្ជសាស្ត្រប្រើជាប់យូរ (DME) បានកាត់បន្ថយមកត្រឹម $0។
- ✓ ថ្មី! អត្ថប្រយោជន៍នៃការមានកូន និងការកសាងគ្រួសារ

ចាប់ពីការមានកូន និងការរៀបចំផែនការគ្រួសាររហូតដល់ការអស់រដូវ—អត្ថប្រយោជន៍ថ្មីរបស់អ្នកផ្តល់នូវការរ៉ាប់រងសម្រាប់ការព្យាបាលចុងក្រោយបំផុត ជំនួយគាំទ្រដែលមានលក្ខណៈផ្ទាល់ខ្លួន ការណែនាំពីអ្នកឥស្សរជនផ្នែកថែទាំអ្នកជំងឺឯកទេស និងការទទួលបានការថែទាំគុណភាពខ្ពស់។




Alyssa E.
អ្នកថែទាំ, Mount Vernon

បន្ថែមពីលើការទទួលបានសេវាធានារ៉ាប់រងសុខភាពដែលមានគុណភាពខ្ពស់ អ្នកអាចទទួលបានអត្ថប្រយោជន៍ឥតគិតថ្លៃផ្សេងទៀត*—បង្កើតឡើងដើម្បីជួយអ្នកកាត់បន្ថយភាពតានតឹង មានសុវត្ថិភាពនៅកន្លែងធ្វើការ និងបង្កើនគុណភាពជីវិតរបស់អ្នក។

ស្វែងយល់បន្ថែមនៅ **myseiu.be/oe-benefits**។

* ច្បាប់នៃសិទ្ធិទទួលបានត្រូវបានអនុវត្ត។

## Caregiver Kicks

## ទ្រនាប់ជើងឥតគិតថ្លៃសម្រាប់អ្នកថែទាំ

ទទួលបានទ្រនាប់ជើងធន់នឹងការរអិលមួយគូដោយឥតគិតថ្លៃជារៀងរាល់ឆ្នាំ! Caregiver Kicks ត្រូវបានផ្តល់ជូនជាង 70 ម៉ូដពី Reebok ដល់ Sketchers ហើយត្រូវបានរចនាឡើងដើម្បីឱ្យអ្នកមានសុវត្ថិភាពជាងមុននៅកន្លែងធ្វើការ ហើយក៏កាត់បន្ថយការឈឺជើង និងខ្នងផងដែរ។



# ទិដ្ឋភាពទូទៅនៃការធានារ៉ាប់រងសុខភាព

ធានារ៉ាប់រងដែលបានរចនាឡើងសម្រាប់អ្នកថែទាំ។



Daniel M.
អ្នកថែទាំ, Lynnwood

**គម្រោងសុខភាព KPWA POS គឺជាគម្រោងចាស់ឈប់ទទួលសមាជិក មានន័យថា គម្រោងនេះមិនអនុញ្ញាតឱ្យមនុស្សថ្មីចូលរួមទេ។ ប្រសិនបើអ្នកចង់ចុះឈ្មោះកូនក្នុងបន្ទុករបស់អ្នក (រហូតដល់អាយុ 26 ឆ្នាំ) ដើម្បីទទួលបានអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ និងធ្មេញ អ្នកត្រូវតែផ្លាស់ប្តូរគម្រោងសុខភាពរបស់អ្នក។**

គម្រោងបច្ចុប្បន្នរបស់អ្នក និងគម្រោងថ្មីដែលមានសម្រាប់អ្នក ផ្តល់ជូននូវការថែទាំ និងជំនួយគាំទ្រដ៏អស្ចារ្យដូចគ្នាសម្រាប់សុខភាព និងសុខុមាលភាពរបស់អ្នក។ ធានារ៉ាប់រងរួមបញ្ចូលអត្ថប្រយោជន៍ដូចខាងក្រោម បូករួមទាំងការចូលប្រើការបណ្តុះបណ្តាលអំពីសុខភាព កម្មវិធីដែលមានលក្ខណៈផ្ទាល់ខ្លួន និងច្រើនទៀត។

- ✓ ការថែទាំបង្ការ
- ✓ វេជ្ជសាស្ត្រ
- ✓ សុខភាពធ្មេញ
- ✓ ទន្តពេទ្យវិទ្យា
- ✓ ឱសថតាមវេជ្ជបញ្ជា
- ✓ សុខភាពផ្លូវអារម្មណ៍
- ✓ ភ្នែក
- ✓ ការស្តាប់
- ✓ ការមានកូន និងការកសាងគ្រួសារ
- ✓ ការថែទាំដែលបញ្ជាក់ពីយេនឌ័រ
- ✓ ការចាប់សរសៃ និងម៉ាស្សា
- ✓ ការព្យាបាលដោយចលនា

## ប្រសិនបើអ្នកប្តូរគម្រោង ការចំណាយរបស់អ្នកសម្រាប់ការធានារ៉ាប់រងលក្ខណៈបុគ្គលនៅតែដដែល។

### ការធានារ៉ាប់រងលក្ខណៈបុគ្គល
### វេជ្ជសាស្ត្រ និងធ្មេញ

**$25/ខែ**

**ទទួលបានការធានារ៉ាប់រងសុខភាពដែលមានគុណភាពខ្ពស់ត្រឹមតែ $25 ក្នុងមួយខែ!**

### Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)
### វេជ្ជសាស្ត្រ និងធ្មេញ

**$100/ខែ**

អ្នកអាចបន្ថែមការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ និងធ្មេញសម្រាប់កុមារដែលមានសិទ្ធិទទួលបានក្នុងតម្លៃ $100 បន្ថែមទៀតក្នុងមួយខែ។

**ប្រាក់ចំណាយដែលបង់ជាមុននៃសហបុព្វលាភប្រចាំខែ៖ $125**

$25 សម្រាប់ការធានារ៉ាប់រងលក្ខណៈបុគ្គល
\+ $100 សម្រាប់កូនរបស់អ្នកទាំងអស់

### Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)
### ធ្មេញតែប៉ុណ្ណោះ

**$10/ខែ**

អ្នកអាចបន្ថែមការធានារ៉ាប់រងផ្នែកធ្មេញប៉ុណ្ណោះសម្រាប់កុមារដែលមានសិទ្ធិទទួលបាន ក្នុងតម្លៃ $10 បន្ថែមទៀតក្នុងមួយខែ។

**ប្រាក់ចំណាយដែលបង់ជាមុននៃសហបុព្វលាភប្រចាំខែ៖ 35$**

$25 សម្រាប់ការធានារ៉ាប់រងលក្ខណៈបុគ្គល
\+ $10 សម្រាប់កូនរបស់អ្នកទាំងអស់

**ការចំណាយគឺដូចគ្នា**
**មិនថាអ្នកបន្ថែមកូនប៉ុន្មាននាក់នោះទេ!**

**ប្រាក់ចំណាយដែលបង់ជាមុននៃសហបុព្វលាភប្រចាំខែ៖** នេះគឺជាចំនួនដែលនិយោជករបស់អ្នកនឹងកាត់ដោយស្វ័យប្រវត្តិពីប្រាក់ឈ្នួលរបស់អ្នករៀងរាល់ខែ។

# តើខ្ញុំក្លាយជាមានសិទ្ធិទទួលបានការធានារ៉ាប់រងដោយរបៀបណា?

## ការធានារ៉ាប់រងលក្ខណៈបុគ្គល

អ្នកត្រូវតែធ្វើការឱ្យបាន **80 ម៉ោង ឬលើសនេះក្នុងមួយខែ**រយៈពេល 2 ខែជាប់ៗគ្នា ដើម្បីមានសិទ្ធិទទួលបានការធានារ៉ាប់រងលក្ខណៈបុគ្គល។

## Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)

អ្នកត្រូវតែធ្វើការឱ្យបាន **120 ម៉ោង ឬលើសនេះក្នុងមួយខែ**ដើម្បីមានសិទ្ធិទទួលបាន Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)។

# តើខ្ញុំអាចដាក់ពាក្យស្នើសុំនៅពេលណា ហើយការធានារ៉ាប់រងនឹងចាប់ផ្តើមនៅពេលណា?

អ្នកអាចដាក់ពាក្យស្នើសុំនៅពេលដែលអ្នកមានសិទ្ធិជាលើកដំបូង ក្នុងអំឡុងពេល Open Enrollment (ការបើកទទួលចុះឈ្មោះ) ឬប្រសិនបើអ្នកមានព្រឹត្តិការណ៍ក្នុងជីវិតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

## ចិរវេលានៃការទទួលបានសិទ្ធិដំបូង

នៅពេលអ្នកទទួលបានសិទ្ធិជាលើកដំបូង ព័ត៌មានស្តីពីការធានារ៉ាប់រងសុខភាព និងរបៀបដាក់ពាក្យនឹងត្រូវបានផ្ញើទៅអ្នក។

អ្នកត្រូវតែបំពេញ និងដាក់ពាក្យស្នើសុំអត្ថប្រយោជន៍សុខភាពរបស់អ្នកក្នុងចន្លោះពេល 60 ថ្ងៃចាប់ពីពេលដែលសិទ្ធិទទួលបានដំបូងត្រូវបានបំពេញ។ ឱកាសបន្ទាប់សម្រាប់អ្នកក្នុងការដាក់ពាក្យគឺ Open Enrollment (ការបើកទទួលចុះឈ្មោះ) ឬរយៈពេលចុះឈ្មោះពិសេស QLE។

**នៅពេលដែលការធានារ៉ាប់រងចាប់ផ្តើមគឺផ្អែកលើកាលបរិច្ឆេទដែលពាក្យសុំដែលបានបំពេញរបស់អ្នកត្រូវបានទទួល។**

វាត្រូវចំណាយពេលប្រហែល 2 សប្តាហ៍ដើម្បីដំណើរការពាក្យសុំរបស់អ្នក ហើយការធានារ៉ាប់រងអាចចាប់ផ្តើមនៅថ្ងៃដំបូងនៃខែប៉ុណ្ណោះ។ យើងសូមណែនាំឱ្យអ្នកដាក់ពាក្យសុំដែលបានបំពេញរបស់អ្នកមុនថ្ងៃទី 15 ដូច្នេះការធានារ៉ាប់រងរបស់អ្នកអាចចាប់ផ្តើមនៅថ្ងៃដំបូងនៃខែបន្ទាប់បាន។

ឧទាហរណ៍ ប្រសិនបើពាក្យស្នើសុំដែលបានបំពេញរបស់អ្នកត្រូវបានទទួល៖

- **ត្រឹមថ្ងៃទី 15 ខែមីនា៖** ការធានារ៉ាប់រងនឹងចាប់ផ្តើមនៅថ្ងៃទី 1 ខែមេសា។
- **រវាងថ្ងៃទី 16 ខែមីនាដល់ថ្ងៃទី 31 ខែមីនា៖** ការធានារ៉ាប់រងនឹងចាប់ផ្តើមនៅថ្ងៃទី 1 ខែឧសភា។

## Open Enrollment (ការបើកទទួលចុះឈ្មោះ)៖ ថ្ងៃទី 1-20 ខែកក្កដា

Open Enrollment (ការបើកទទួលចុះឈ្មោះ) គឺជាឱកាសប្រចាំឆ្នាំរបស់អ្នកក្នុងការដាក់ពាក្យ ឬធ្វើការផ្លាស់ប្តូរលើការធានារ៉ាប់រងរបស់អ្នក។ ថ្ងៃទី 20 ខែកក្កដា គឺជាថ្ងៃផុតកំណត់របស់អ្នកដើម្បីដាក់ពាក្យស្នើសុំធានារ៉ាប់រងការថែទាំសុខភាព ឬធ្វើការផ្លាស់ប្តូរប្រសិនបើអ្នកបានចុះឈ្មោះរួចហើយ។ ការផ្លាស់ប្តូររួមមានការផ្លាស់ប្តូរគម្រោងសុខភាពធ្មេញរបស់អ្នក ឬការបន្ថែម Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)។

**ធានារ៉ាប់រងនឹងចាប់ផ្តើមនៅថ្ងៃទី 1 ខែសីហា ឆ្នាំ 2024។**

## ចិរវេលាទទួលចុះឈ្មោះពិសេស 30-ថ្ងៃ សម្រាប់ ព្រឹត្តិការណ៍ក្នុងជីវិតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QLE)

ព្រឹត្តិការណ៍ក្នុងជីវិតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ គឺជាការផ្លាស់ប្តូរនៅក្នុងស្ថានភាពជីវិតរបស់អ្នក ដែលអាចធ្វើឱ្យអ្នកមានសិទ្ធិទទួលបានអំឡុងពេលចុះឈ្មោះពិសេស។ ឧទាហរណ៍នៃព្រឹត្តិការណ៍ជីវិតរួមមានការយកកូនមកចិញ្ចឹម ការបាត់បង់ការធានារ៉ាប់រងសុខភាពផ្សេងទៀត ឬការលែងលះ។ សម្រាប់បញ្ជីពេញលេញនៃ QLE សូមចូលមើល **myseiu.be/qle**។

មធ្យោបាយងាយស្រួលបំផុតដើម្បីដាក់ស្នើ QLE គឺដោយប្រើគណនីអនឡាញរបស់អ្នក ហើយ QLE ត្រូវតែដាក់ជូនក្នុងចន្លោះពេល 30 ថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍របស់អ្នក។



## មិនមានសិទ្ធិឥឡូវនេះមែនទេ?

### អ្នកនៅតែអាចស្នើសុំការធានារ៉ាប់រងក្នុងអំឡុងពេល Open Enrollment (ការបើកទទួលចុះឈ្មោះ) បាន។

បំពេញពាក្យស្នើសុំអត្ថប្រយោជន៍សុខភាពសម្រាប់ខ្លួនអ្នក ហើយធានារ៉ាប់រងលក្ខណៈបុគ្គលនឹងចាប់ផ្តើមនៅពេលអ្នកចាប់ផ្តើមធ្វើការដល់ចំនួន 80 ម៉ោង ឬច្រើនជាងនេះក្នុងមួយខែ។ អ្នកក៏អាចបន្ថែមកុមារទៅក្នុងពាក្យស្នើសុំអត្ថប្រយោជន៍សុខភាពរបស់អ្នកបានផងដែរ ហើយ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) នឹងចាប់ផ្តើមនៅពេលអ្នកចាប់ផ្តើមធ្វើការដល់ចំនួន 120 ម៉ោង ឬច្រើនជាងនេះក្នុងមួយខែ។

# តើខ្ញុំអាចធ្វើការផ្លាស់ប្តូរនៅពេលណា ហើយការធានារ៉ាប់រងនឹងចាប់ផ្តើមនៅពេលណា?

## Open Enrollment (ការបើកទទួលចុះឈ្មោះ)៖ ថ្ងៃទី 1-20 ខែកក្កដា

Open Enrollment (ការបើកទទួលចុះឈ្មោះ) គឺជាឱកាសប្រចាំឆ្នាំរបស់អ្នកក្នុងការដាក់ពាក្យ ឬធ្វើការផ្លាស់ប្តូរលើការធានារ៉ាប់រងរបស់អ្នក។ ថ្ងៃទី 20 ខែកក្កដា គឺជាថ្ងៃផុតកំណត់របស់អ្នកដើម្បីដាក់ពាក្យស្នើសុំធានារ៉ាប់រងការថែទាំសុខភាព ឬធ្វើការផ្លាស់ប្តូរប្រសិនបើអ្នកបានចុះឈ្មោះរួចហើយ។ ការផ្លាស់ប្តូររួមមានការផ្លាស់ប្តូរគម្រោងសុខភាពធ្មេញរបស់អ្នក ឬការបន្ថែម Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)។

**ធានារ៉ាប់រងនឹងចាប់ផ្តើមនៅថ្ងៃទី 1 ខែសីហា ឆ្នាំ 2024។**

**ប្រសិនបើអ្នកមិនកំពុងធ្វើការ 120 ម៉ោងក្នុងពេលនេះទេ អ្នកនៅតែអាចប្តូរគម្រោង និងដាក់ពាក្យក្នុងអំឡុងពេល Open Enrollment (ការបើកទទួលចុះឈ្មោះ)។** បំពេញពាក្យស្នើសុំអត្ថប្រយោជន៍សុខភាព ហើយ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) នឹងចាប់ផ្តើមនៅពេលអ្នកចាប់ផ្តើមធ្វើការ 120 ម៉ោង ឬច្រើនជាងនេះក្នុងមួយខែ។

## ថិរវេលាទទួលចុះឈ្មោះពិសេស 30-ថ្ងៃ សម្រាប់ ព្រឹត្តិការណ៍ក្នុងជីវិតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QLE)

ព្រឹត្តិការណ៍ក្នុងជីវិតដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ គឺជាការផ្លាស់ប្តូរនៅក្នុងស្ថានភាពជីវិតរបស់អ្នក ដែលអាចធ្វើឱ្យអ្នកមានសិទ្ធិទទួលបានអំឡុងពេលចុះឈ្មោះពិសេស។ ឧទាហរណ៍នៃព្រឹត្តិការណ៍ជីវិតរួមមានការយកកូនមកចិញ្ចឹម ការបាត់បង់ការធានារ៉ាប់រងសុខភាពផ្សេងទៀត ឬការលែងលះ។ សម្រាប់បញ្ជីពេញលេញនៃ QLE សូមចូលមើល **myseiu.be/qle**។

មធ្យោបាយងាយស្រួលបំផុតដើម្បីដាក់ស្នើ QLE គឺដោយប្រើគណនីអនឡាញរបស់អ្នក ហើយ QLE ត្រូវតែដាក់ជូនក្នុងចន្លោះពេល 30 ថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍របស់អ្នក។

# តើខ្ញុំធ្វើការផ្លាស់ប្តូរ ឬប្តូរគម្រោងដោយរបៀបណា?

## មធ្យោបាយងាយស្រួលបំផុតគឺតាមអនឡាញនៅ **myseiu.be/oe-online**។

**ដើម្បីធ្វើការផ្លាស់ប្តូរតាមសំបុត្រប្រៃសណីយ៍ ឬទូរសារ៖** ប្រសិនបើអ្នកបានទទួលមគ្គុទ្ទេសក៍អត្ថប្រយោជន៍សុខភាពដែលបានបោះពុម្ព អ្នកអាចប្រើកម្មវិធីអត្ថប្រយោជន៍សុខភាពដែលមាននៅក្នុងសំបុត្រប្រៃសណីយ៍របស់អ្នកបាន។ ផ្ញើសំបុត្រប្រៃសណីយ៍ ឬទូរសារនូវពាក្យសុំដែលបានបំពេញរបស់អ្នក ទៅកាន់អាសយដ្ឋាន ឬលេខទូរសារដែលមានរាយក្នុងពាក្យសុំអត្ថប្រយោជន៍សុខភាព។ តម្រូវឱ្យមានការបង់ថ្លៃប្រៃសណីយ៍នៅសហរដ្ឋអាមេរិក។

**ដើម្បីប្តូរគម្រោងតាមប្រៃសណីយ៍ ឬទូរសារ៖** សូមទូរសព្ទទៅលេខ 877-606-6705 ដើម្បីប្តូរគម្រោង ហើយអ្នកនឹងទទួលបានមគ្គុទេសក៍អត្ថប្រយោជន៍សុខភាពថ្មី និងពាក្យស្នើសុំចុះឈ្មោះសម្រាប់គម្រោងសុខភាពថ្មីរបស់អ្នក (ត្រូវបានចាត់តាំងអាស្រ័យលើលេខកូដតំបន់របស់អ្នក) ជាមួយនឹងការណែនាំអំពីរបៀបធ្វើការផ្លាស់ប្តូរ។

# តើខ្ញុំរក្សាការធានារ៉ាប់រងដោយរបៀបណា?

អ្នកត្រូវតែបន្តធ្វើការដល់ចំនួនម៉ោងដែលត្រូវបានតម្រូវក្នុងមួយខែ និង បង់ប្រាក់ចំណាយដែលបង់ជាមុននៃបុព្វលាភរ៉ាប់រងរួមប្រចាំខែរបស់អ្នកទាន់ពេល ដើម្បីរក្សាការធានារ៉ាប់រងសុខភាពបន្តបន្ទាប់។ ដោយសារការធានារ៉ាប់រងដែលមានលក្ខណៈផ្ទាល់ខ្លួនរបស់អ្នក និង Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) មានលក្ខខណ្ឌតម្រូវនៃចំនួនម៉ោងខុសៗគ្នា អ្នកអាចបាត់បង់ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) ប៉ុន្តែនៅតែរក្សាការធានារ៉ាប់រងលក្ខណៈបុគ្គលរបស់អ្នក។ ស្វែងយល់បន្ថែមអំពីរបៀបដែលចំនួនម៉ោងធ្វើការមានឥទ្ធិពលលើការធានារ៉ាប់រងរបស់អ្នកនៅទំព័របន្ទាប់។

## ដើម្បីរក្សាការធានារ៉ាប់រងលក្ខណៈបុគ្គល អ្នកត្រូវ៖

- ✓ ធ្វើការ 80 ម៉ោងឬច្រើនជាងនេះក្នុងមួយខែ។
- ✓ រាយការណ៍ចំនួនម៉ោងរបស់អ្នកក្នុងរយៈពេល 60 ថ្ងៃនៃខែដែលបានធ្វើការ។
- ✓ បង់ប្រាក់ចំណាយដែលត្រូវបង់ជាមុនសហបុព្វលាភប្រចាំខែ $25 របស់អ្នក។

## ដើម្បីរក្សា Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) អ្នកត្រូវតែ៖

- ✓ ធ្វើការ 120 ម៉ោងឬច្រើនជាងនេះក្នុងមួយខែ។
- ✓ រាយការណ៍ចំនួនម៉ោងរបស់អ្នកក្នុងរយៈពេល 60 ថ្ងៃនៃខែដែលបានធ្វើការ។
- ✓ បង់ប្រាក់ចំណាយដែលត្រូវបង់ជាមុនសហបុព្វលាភប្រចាំខែពេញលេញសម្រាប់អ្នក និងកូនក្នុងបន្ទុករបស់អ្នក។

## ! រាយការណ៍ចំនួនម៉ោងរបស់អ្នកឱ្យទាន់ពេលវេលា

### ដើម្បីរក្សាការធានារ៉ាប់រងរបស់អ្នក

**អ្នកនឹងបាត់បង់ការធានារ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកមិនរាយការណ៍ចំនួនម៉ោងឱ្យទាន់ពេលវេលា។** អ្នកអាចដាក់បញ្ជូនចំនួនម៉ោងយឺតយ៉ាវ ឬធ្វើការកែតម្រូវជាមួយនិយោជករបស់អ្នកក្នុងរយៈពេល 60 ថ្ងៃនៃខែដែលបានធ្វើការ។

## ! ស្វែងរកចំនួនម៉ោងបន្ថែម

### ដើម្បីរក្សាការធានារ៉ាប់រងរបស់អ្នក

ប្រសិនបើអ្នកជាអ្នកផ្តល់សេវាលក្ខណៈបុគ្គល (IP) ហើយត្រូវការចំនួនម៉ោងបន្ថែមដើម្បីទទួលបាន ឬរក្សាការធានារ៉ាប់រង សូមសាកល្បង Carina ដែលជាគេហទំព័រផ្គូផ្គងការងារឥតគិតថ្លៃដែលជួយអ្នកស្វែងរកអ្នកជំងឺកាន់តែច្រើន។ ស្វែងយល់បន្ថែមនៅ**myseiu.be/oe-carina**។

# តើចំនួនម៉ោងដែលខ្ញុំធ្វើការមានឥទ្ធិពលដល់ការរក្សាការធានារ៉ាប់រងយ៉ាងដូចម្តេច?

| ខែធ្វើការ | | ខែធានារ៉ាប់រង |
|---|---|---|
| ចំនួនម៉ោងដែលអ្នកធ្វើការក្នុងខែនេះ៖ | | កំណត់ការធានារ៉ាប់រងក្នុងខែនេះ៖ |
| ខែមករា | → | ខែមីនា |
| ខែកុម្ភៈ | → | ខែមេសា |
| ខែមីនា | → | ខែឧសភា |
| ខែមេសា | → | ខែមិថុនា |
| ខែឧសភា | → | ខែកក្កដា |
| ខែមិថុនា | → | ខែសីហា |
| ខែកក្កដា | → | ខែកញ្ញា |
| ខែសីហា | → | ខែតុលា |
| ខែកញ្ញា | → | ខែវិច្ឆិកា |
| ខែតុលា | → | ខែធ្នូ |
| ខែវិច្ឆិកា | → | ខែមករា |
| ខែធ្នូ | → | ខែកុម្ភៈ |

### ចំនួនម៉ោងដែលអ្នកធ្វើការកំណត់ស្ថានភាពធានារ៉ាប់រងសុខភាពរបស់អ្នក 2 ខែក្រោយ។

សូមមើលឧទាហរណ៍ខាងក្រោមអំពីរបៀបដែលចំនួនម៉ោងរបស់អ្នកក្នុងខែមិថុនាមានឥទ្ធិពលដល់ការធានារ៉ាប់រងក្នុងខែសីហា។

### ការបាត់បង់ការធានារ៉ាប់រងលក្ខណៈបុគ្គល

| ខែធ្វើការ៖ ខែមិថុនា | ខែធានារ៉ាប់រង៖ ខែសីហា |
|---|---|
| អ្នកធ្វើការតិចជាង 80 ម៉ោង។ | អ្នកបាត់បង់ការធានារ៉ាប់រង។ |

### ការបាត់បង់ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)

ដោយសារការធានារ៉ាប់រងលក្ខណៈបុគ្គល និង Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) មានលក្ខខណ្ឌតម្រូវនៃចំនួនម៉ោងខុសៗគ្នា អ្នកអាចបាត់បង់ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) ប៉ុន្តែរក្សាការធានារ៉ាប់រងលក្ខណៈបុគ្គល។

| ខែធ្វើការ៖ ខែមិថុនា | ខែធានារ៉ាប់រង៖ ខែសីហា |
|---|---|
| អ្នកធ្វើការលើសពី 80 ម៉ោង ប៉ុន្តែតិចជាង 120 ម៉ោង។ | អ្នករក្សាការធានារ៉ាប់រងលក្ខណៈបុគ្គល ប៉ុន្តែបាត់បង់ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)។ |

### ការទទួលបានធានារ៉ាប់រងឡើងវិញដោយស្វ័យប្រវត្តិ

ប្រសិនបើអ្នកបាត់បង់ការធានារ៉ាប់រងដោយសារតែចំនួនម៉ោងមិនគ្រប់គ្រាន់ នៅពេលក្រោយមកទៀតដែលអ្នកធ្វើការគ្រប់ចំនួនម៉ោងដែលតម្រូវក្នុងខែធ្វើការ ការធានារ៉ាប់រងរបស់អ្នកនឹងបន្តដោយស្វ័យប្រវត្តិនៅក្នុងខែនៃការធានារ៉ាប់រងដែលពាក់ព័ន្ធ។

| ខែធ្វើការ៖ ខែមិថុនា | ខែធានារ៉ាប់រង៖ ខែសីហា |
|---|---|
| អ្នកធ្វើការគ្រប់ចំនួនម៉ោងដែលតម្រូវ។ | ការធានារ៉ាប់រងបន្តដោយស្វ័យប្រវត្តិ។ |

! នៅពេលដែលការធានារ៉ាប់រងត្រូវបានបន្តឡើងវិញ និយោជករបស់អ្នកមិនអាចកាត់ប្រាក់សហប្រាក់ពលាភប្រចាំខែដោយស្វ័យប្រវត្តិបានទេ ហើយអ្នកនឹងទទួលបានការជូនដំណឹងអំពីការបង់ប្រាក់ដោយខ្លួនឯង។ **ប្រសិនបើអ្នកមានគម្លាតក្នុងការធានារ៉ាប់រង 12 ខែ ឬច្រើនជាងនេះ អ្នកនឹងត្រូវដាក់ពាក្យសុំការធានារ៉ាប់រងលើការថែទាំសុខភាពឡើងវិញ។**

# តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំបាត់បង់ការធានារ៉ាប់រង?

## ប្រសិនបើអ្នកបាត់បង់ការធានារ៉ាប់រងសុខភាព អ្នកនឹងទទួលបានព័ត៌មានអំពីការបន្តការធានារ៉ាប់រងតាមរយៈ COBRA។

**COBRA៖** (ច្បាប់ស្តីពីដំណើរសម្របសម្រួលថវិកា Omnibus រួម) ជួយអ្នកថែទាំ និងកូនរបស់ពួកគាត់ដែលបានបាត់បង់ការធានារ៉ាប់រងសុខភាព។ តាមរយៈ COBRA នៅពេលអ្នកបាត់បង់ការធានារ៉ាប់រងរបស់អ្នក ឬ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) អ្នកអាចទទួលបានការធានារ៉ាប់រងបន្តលើការថែទាំសុខភាពសម្រាប់ការបង់ប្រាក់ប្រចាំខែ។ អត្ថប្រយោជន៍ COBRA របស់អ្នកត្រូវបានគ្រប់គ្រងដោយ Ameriflex។ សម្រាប់សំណួរអំពី COBRA សូមហៅទូរសព្ទទៅសេវាបម្រើអតិថិជន៖ **1-877-606-6705**។

**ជម្រើសធានារ៉ាប់រងលើការថែទាំសុខភាពផ្សេងទៀត៖** ប្រសិនបើអ្នកបានឈប់ផ្តល់ការថែទាំ ហើយត្រូវការស្វែងរកការធានារ៉ាប់រងសុខភាពរយៈពេលវែង សូមចូលទៅកាន់ **wahealthplanfinder.org**។ អ្នកអាចស្វែងយល់ថាតើអ្នកមានសិទ្ធិទទួលបាន Washington Apple Health ដោយឥតគិតថ្លៃឬអត់ ឬប្រៀបធៀបជម្រើសថែទាំសុខភាពផ្សេងទៀតបាន។

# Coverage for Kids

## (ការធានារ៉ាប់រងសម្រាប់កុមារ)

**ប្តូរគម្រោងសុខភាពរបស់អ្នក ដើម្បីទទួលបានការធានារ៉ាប់រងដ៏អស្ចារ្យដូចគ្នាសម្រាប់កូនក្នុងបន្ទុករបស់អ្នក។**




## ប្រសិនបើអ្នកចង់បន្ថែមកុមារទៅការធានារ៉ាប់រងសុខភាពរបស់អ្នក៖

- ✓ **ប្តូរគម្រោងសុខភាពរបស់អ្នក។** ជារឿងងាយស្រួលក្នុងការប្តូរគម្រោងសុខភាពរបស់អ្នក ឬផ្លាស់ប្តូរគម្រោងសុខភាពធ្មេញរបស់អ្នកនៅ myseiu.be/oe-online។ ឬទូរសព្ទទៅ 1-877-606-6705 ដើម្បីប្តូរគម្រោង ហើយអ្នកនឹងទទួលបានមគ្គុទេសក៍អត្ថប្រយោជន៍សុខភាពថ្មី និងពាក្យស្នើសុំចុះឈ្មោះសម្រាប់គម្រោងសុខភាពថ្មីរបស់អ្នក (ត្រូវបានចាត់តាំងអាស្រ័យលើលេខកូដតំបន់របស់អ្នក)។
- ✓ **ធ្វើការយ៉ាងហោចណាស់ 120 ម៉ោងក្នុងមួយខែ។** ប្រសិនបើអ្នកមិនមានសិទ្ធិឥឡូវនេះទេ អ្នកអាចបំពេញពាក្យសុំក្នុងអំឡុង Open Enrollment (ការបើកទទួលចុះឈ្មោះ) ហើយ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) នឹងចាប់ផ្តើមនៅពេលអ្នកចាប់ផ្តើមធ្វើការដល់ចំនួន 120 ម៉ោង ឬច្រើនជាងនេះក្នុងមួយខែ។
- ✓ **បំពេញផ្នែក Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ) ក្នុងពាក្យសុំអត្ថប្រយោជន៍សុខភាព** តាមអ៊ីនធឺណិត ឬតាមសំបុត្រប្រៃសណីយ៍។ អ្នកនឹងត្រូវជ្រើសរើសជម្រើសធានារ៉ាប់រងសម្រាប់កូនរបស់អ្នក (វេជ្ជសាស្ត្រ និងធ្មេញតម្លៃ ឬសម្រាប់តែធ្មេញ)។
- ✓ **ដាក់បញ្ជូនឯកសារផ្ទៀងផ្ទាត់អ្នកនៅក្នុងបន្ទុក**ដើម្បីផ្ទៀងផ្ទាត់ទំនាក់ទំនងរបស់អ្នកជាមួយកូនៗរបស់អ្នកជាមួយនឹងពាក្យសុំ។
- ✓ **បង់សហបុព្វលាភប្រចាំខែដែលត្រូវការ**សម្រាប់ជម្រើសនៃការធានារ៉ាប់រងដែលអ្នកបានជ្រើសរើសសម្រាប់កូនៗរបស់អ្នក។

## តើខ្ញុំអាចបន្ថែមអ្នកណាទៅ Coverage for Kids (ការធានារ៉ាប់រងសម្រាប់កុមារ)?

អ្នកអាចបន្ថែមកុមារដែលមានសិទ្ធិគ្រប់គ្រាន់ (រហូតដល់ថ្ងៃកំណើតទី 26 របស់ពួកគាត់)។ ឧទាហរណ៍មួយចំនួននៃកូនក្នុងបន្ទុកដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់គឺ កូនបង្កើត កូនចិញ្ចឹម កូនចុង និងកូនរបស់ដៃគូក្នុងគ្រួសាររបស់អ្នក។

## តើត្រូវការអ្វីខ្លះសម្រាប់ការផ្ទៀងផ្ទាត់អ្នកនៅក្នុងបន្ទុក?

**នៅពេលអ្នកចុះឈ្មោះកូនរបស់អ្នកលើកដំបូង អ្នកនឹងត្រូវផ្ទៀងផ្ទាត់ទំនាក់ទំនងរបស់អ្នកជាមួយពួកគេ មុនពេលដែលការធានារ៉ាប់រងអាចចាប់ផ្តើម។*** យើងសូមណែនាំឱ្យអ្នកដាក់បញ្ជូនឯកសារផ្ទៀងផ្ទាត់អ្នកនៅក្នុងបន្ទុករបស់អ្នកអមជាមួយពាក្យសុំអត្ថប្រយោជន៍សុខភាពដែលបានបំពេញរបស់អ្នកត្រឹមថ្ងៃទី 20 ខែកក្កដា។ ប្រសិនបើអ្នកមិនអាចធ្វើដូច្នេះបានទេ អ្នកត្រូវតែបញ្ជូនឯកសាររបស់អ្នកត្រឹម **ថ្ងៃទី 30 ខែកញ្ញា** ហើយត្រូវប្រាកដថាដាក់ស្លាកវាជាមួយនឹងនាមខ្លួន និងនាមត្រកូលរបស់អ្នក និងលេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។

*ប្រសិនបើអ្នកបានបញ្ជូនឯកសារដែលបានផ្ទៀងផ្ទាត់រួចហើយ អ្នកមិនចាំបាច់ផ្ញើឯកសាររបស់អ្នកឡើងវិញទេ លុះត្រាតែវាត្រូវបានស្នើសុំ។

## ឯកសារដែលទទួលយកសម្រាប់ការផ្ទៀងផ្ទាត់អ្នកនៅក្នុងបន្ទុក

**អ្នកត្រូវដាក់បញ្ជូនឯកសារផ្ទៀងផ្ទាត់អ្នកនៅក្នុបន្ទុកមួយសម្រាប់កូននីមួយៗដែលអ្នកចុះឈ្មោះ។** ឧទាហរណ៍ឯកសារមួយចំនួនដែលអាចយកមកប្រើដើម្បីធ្វើការផ្ទៀងផ្ទាត់អ្នកនៅក្នុងបន្ទុករួមមាន៖

- ច្បាប់ចម្លងសំបុត្រកំណើតរបស់កូនអ្នក។
- ច្បាប់ចម្លងលិខិតបញ្ជាក់កូនចិញ្ចឹម អាណាព្យាបាលស្របច្បាប់ ឬសំបុត្រស្មុំកូន។
- ច្បាប់ចម្លងលិខិតប្រកាសពន្ធសហព័ន្ធថ្មីៗបំផុតរបស់អ្នក ដែលរាយនាមអ្នកនៅក្នុងបន្ទុករបស់អ្នក។
- ឯកសារបន្ថែមអាចត្រូវបានត្រូវការ ប្រសិនបើអ្នកកំពុងបន្ថែមកូនរបស់ដៃគូក្នុងគ្រួសារ។

**សម្រាប់បញ្ជីពេញលេញនៃអ្នកដែលមានលក្ខណៈគ្រប់គ្រាន់ជាកូនក្នុងបន្ទុក និងឯកសារដែលទទួលយក សូមចូលទៅកាន់ myseiu.be/cfk។**

# គ្រប់គ្រងអត្ថប្រយោជន៍សុខភាពរបស់អ្នកដោយប្រើគណនីអនឡាញ

**ចាប់ផ្ដើមនៅ myseiu.be/oe-online**







## តាមរយៈគណនី អ្នកអាច៖

- ✓ មើលចំនួនម៉ោង និងសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាព Caregiver Kicks និងកម្មវិធី Headspace Care។
- ✓ ធ្វើការផ្លាស់ប្ដូរលើការធានារ៉ាប់រងសុខភាព។
- ✓ បន្ថែមកុមារទៅក្នុងការធានារ៉ាប់រងរបស់អ្នក។
- ✓ ចូលប្រើឯកសារ និងទម្រង់ផែនការផ្សេងៗ។
- ✓ បង់សហបុព្វលាភ និងមើលប្រវត្តិទូទាត់។
- ✓ ចុះឈ្មោះសម្រាប់ទំនាក់ទំនងតាមអ៊ីមែលអំពីការធានារ៉ាប់រង។

## ការបង្កើតគណនីគឺងាយស្រួល - ចំណាយពេលត្រឹមតែ 5 នាទីប៉ុណ្ណោះ!

ចូលទៅកាន់ **myseiu.be/oe-online** សម្រាប់វីដេអូបង្រៀនអំពីការបង្កើតគណនីថ្មី។

គណនីអនឡាញគឺជាផ្នែកមួយនៃវិបសាយ CREATE របស់ MagnaCare។ MagnaCare គឺជាអ្នកគ្រប់គ្រងការធានារ៉ាប់រងសុខភាពរបស់អ្នក។ គេហទំព័រនេះមានជាភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបង្កើតគណនី ឬជំនួយផ្នែកភាសា សូមទូរសព្ទទៅផ្នែកសេវាបម្រើអតិថិជន៖ **1-877-606-6705**។

# ព័ត៌មានសង្ខេបសំខាន់ៗនៃគម្រោងសុខភាព

KAISER PERMANENTE®



Becky F.
អ្នកថែទាំ Lacey

## ទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនបំផុតពីការធានារ៉ាប់រងសុខភាព Kaiser Permanente of Washington (KPWA POS) របស់អ្នក។

លើសពីការថែទាំបង្ការ ការធានារ៉ាប់រងរបស់អ្នករួមបញ្ចូលវិធីជាច្រើនដើម្បីទទួលបានការថែទាំ និងការគាំទ្រ ដូចជាការបណ្តុះបណ្តាលសុខភាព និងកម្មវិធីគ្រប់គ្រងដែលមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់ស្ថានភាពរ៉ាំរ៉ៃដូចជាជំងឺទឹកនោមផ្អែម លើសឈាម និងឈឺខ្នងជាដើម។

ត្រូវប្រាកដថាស្វែងយល់អំពីទិដ្ឋភាពទាំងអស់នៃគម្រោងសុខភាពរបស់អ្នក និងទាញយកអត្ថប្រយោជន៍ដ៏អស្ចារ្យបំផុតរបស់អ្នក!

## ប្រើលេខសម្គាល់សមាជិករបស់អ្នកដើម្បីចាប់ផ្តើម

នៅពេលអ្នកបានចុះឈ្មោះរួច Kaiser Permanente នឹងផ្ញើកាត ID សមាជិកមកអ្នកតាមប្រៃសណីយ៍។ ប្រសិនបើអ្នកមិនទទួលបានកាតរបស់អ្នកក្នុងរយៈពេល 10 ថ្ងៃនៃថ្ងៃធ្វើការចាប់ពីថ្ងៃចាប់ផ្តើមការធានារ៉ាប់រង សូមទូរសព្ទទៅផ្នែកសេវាបម្រើសមាជិក Kaiser Permanente។

តាមរយៈកាតសម្គាល់ខ្លួនសមាជិករបស់អ្នក អ្នកអាចបង្កើតគណនីដែលមានសុវត្ថិភាព និងគ្រប់គ្រងសុខភាពរបស់អ្នកតាមអ៊ីនធឺណិតនៅ **kp.org/wa** និងតាមរយៈកម្មវិធីទូរសព្ទ Kaiser Permanente។

Kaiser Permanente of Washington (KPWA) គឺជាគម្រោងសុខភាពដែលមានផ្តល់ជូនអ្នក ដោយផ្អែកលើលេខកូដតំបន់របស់អ្នក។

## ការទៅជួបទទួលការថែទាំបឋមដោយឥតគិតថ្លៃ*

តាមរយៈ Kaiser Permanente មិនមានការបង់ប្រាក់ចំណាយផ្ទាល់ខ្លួនទេ នៅពេលអ្នកជួបវេជ្ជបណ្ឌិតថែទាំបឋមរបស់អ្នក (ហៅម្យ៉ាងទៀតថាអ្នកផ្តល់សេវាថែទាំបឋម ឬ PCP)។ អ្នកអាចទៅជួប PCP របស់អ្នកដើម្បីធ្វើការពិនិត្យសុខភាព នៅពេលអ្នកឈឺ។ Kaiser Permanente ក៏ផ្តល់ជម្រើសការថែទាំតាមអ៊ីនធឺណិតនៅក្នុងករណីជាច្រើនផងដែរ ដូច្នេះអ្នកអាចទទួលបានការថែទាំពីផ្ទះរបស់អ្នកយ៉ាងសុខស្រួល។

*ការទៅជួប PCP របស់អ្នកមិនមានការបង់ប្រាក់ចំណាយផ្ទាល់ខ្លួនទេ ប៉ុន្តែប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកបញ្ជាឱ្យធ្វើតេស្ត ឬការងារមន្ទីរពិសោធន៍ អ្នកប្រហែលជាត្រូវបង់ប្រាក់ចំណាយផ្ទាល់ខ្លួនលើសេវាទាំងនោះ។

## ការថែទាំបន្ទាន់ និងសង្គ្រោះបន្ទាន់

ប្រសិនបើអ្នកមិនអាចទទួលបានការណាត់ជួបនៅថ្ងៃតែមួយជាមួយវេជ្ជបណ្ឌិតរបស់អ្នក ឬមានតម្រូវការសុខភាពភ្លាមៗនោះ មជ្ឈមណ្ឌលថែទាំបន្ទាន់របស់ Kaiser Permanente ដែលនៅជិតបំផុតរបស់អ្នកគឺជាដំណោះស្រាយដែលមានតម្លៃសមរម្យ។

| | |
|---|---|
| **អ្នកផ្តល់សេវាថែទាំបឋម/ការពិនិត្យសុខភាពតាមអ៊ីនធឺណិត** | **ប្រាក់ចំណាយផ្ទាល់ខ្លួន $0** |
| **ការជួបថែទាំជាបន្ទាន់** | **ប្រាក់ចំណាយផ្ទាល់ខ្លួន $0** |
| **ការចូលបន្ទប់សង្គ្រោះបន្ទាន់** | **ប្រាក់ចំណាយផ្ទាល់ខ្លួន $200** |

## អត្ថប្រយោជន៍ឱសថតាមវេជ្ជបញ្ជា

អត្ថប្រយោជន៍ឱសថតាមវេជ្ជបញ្ជា (Rx) ត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រងរបស់អ្នក ហើយការផ្ទេរវេជ្ជបញ្ជារបស់អ្នកគឺសាមញ្ញ! គ្រាន់តែចូលទៅក្នុងគណនីអនឡាញ Kaiser Permanente របស់អ្នក ឬទូរសព្ទទៅសេវាបម្រើសមាជិក។

ការបញ្ជាទិញតាមប្រៃសណីយ៍គឺជាជម្រើសដែលមានតម្លៃសមរម្យបំផុតសម្រាប់អ្នកដើម្បីទទួលបានវេជ្ជបញ្ជារបស់អ្នក។ បើកថ្នាំតាមវេជ្ជបញ្ជារបស់អ្នកតាមអ៊ីនធឺណិត តាមទូរសព្ទ ឬប្រើកម្មវិធីរបស់ Kaiser Permanente។

## អត្ថប្រយោជន៍សុខភាពផ្លូវចិត្ត និងសុខុមាលភាព

សុខភាពផ្លូវអារម្មណ៍របស់អ្នកសំខាន់ដូចគ្នាទៅនឹងសុខភាពផ្លូវកាយរបស់អ្នកដែរ។ ការធានារ៉ាប់រងរបស់ Kaiser Permanente រួមមានការគាំទ្រប្រកបដោយវិជ្ជាជីវៈ ការប្រើថ្នាំ ការព្យាបាលដោយក្រុមគ្រូពេទ្យ និងការថែទាំជំនួស ក៏ដូចជា៖

- ចូលប្រើកម្មវិធីសុខភាពផ្លូវអារម្មណ៍ និងការថែទាំខ្លួនឯងដោយឥតគិតថ្លៃ ដូចជា Calm សម្រាប់សតិដឹង និង Headspace Care សម្រាប់ការបណ្តុះបណ្តាលផ្លូវអារម្មណ៍មួយទល់មួយ។
- ការជជែកអំពីការថែទាំសុខភាពផ្លូវចិត្ត ដែលអ្នកអាចរៀបចំការថែទាំសុខភាពផ្លូវចិត្តបានយ៉ាងងាយស្រួលតាមអ៊ីនធឺណិត។
- ការវាយតម្លៃតាមអ៊ីនធឺណិត និងការពិនិត្យតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីពិនិត្យមើលរោគសញ្ញារបស់អ្នក និងទទួលបានជម្រើសដែលស័ក្តិសមសម្រាប់អ្នក។

ស្វែងយល់បន្ថែមនៅ **myseiu.be/kaiser-bh**។

## អត្ថប្រយោជន៍ភ្នែក (បានបន្ថែម!)

Kaiser Permanente ផ្តល់ការថែទាំភ្នែកយ៉ាងទូលំទូលាយ។ ចំណុចនេះរួមបញ្ចូលទាំងការពិនិត្យភ្នែកដោយឥតគិតថ្លៃ 1 ដងរៀងរាល់ 12 ខែម្តង និង $600 រៀងរាល់ 12 ខែសម្រាប់ឧបករណ៍ជំនួយគំហើញ (ដូចជាកញ្ចក់ ស៊ុម និងកញ្ចក់ពាក់កែវភ្នែក)។ អ្នកអាចជ្រើសរើសពីបណ្តុំរ៉ែនតាដែលមានគុណភាពខ្ពស់ដែលស័ក្តិសមនឹងរចនាប័ទ្ម និងថវិការបស់អ្នក។ ការកែតម្រូវ និងការជួសជុលគឺតែងតែមិនគិតថ្លៃ។

## អត្ថប្រយោជន៍ការស្តាប់ (បានបន្ថែម!)

ការបាត់បង់សមត្ថភាពស្តាប់គឺជាជំងឺទូទៅមួយ ប៉ុន្តែវាក៏អាចព្យាបាលបានផងដែរ។ តាមរយៈ EPIC Hearing អ្នកអាចទទួលបានការពិនិត្យសមត្ថភាពនៃការស្តាប់ប្រចាំឆ្នាំដោយមិនគិតថ្លៃពីអ្នកផ្តល់សេវាថែទាំជាដៃគូផ្នែកការស្តាប់របស់ EPIC និងរហូតដល់ $3,000 នៃឧបករណ៍ជំនួយការស្តាប់សម្រាប់ត្រចៀកនីមួយៗរៀងរាល់ 36 ខែដោយមិនគិតថ្លៃសម្រាប់អ្នក។
ចាប់ផ្តើមតាមរយៈ **myseiu.be/epic**។

EPIC HEARING HEALTHCARE

| ប្រាក់ចំណាយផ្ទាល់ខ្លួន Rx | ឱសថស្ថានការផ្គត់ផ្គង់ 30 ថ្ងៃ | ការបញ្ជាតាមប្រៃសណីយ៍ការផ្គត់ផ្គង់ 90 ថ្ងៃ |
|---|---|---|
| ថ្នាំពន្យារកំណើតទូទៅ* | $0 | $0 |
| ឱសថផ្អែកតាមតម្លៃ** | $4 | $8 |
| ឱសថទូទៅដែលនិយមប្រើ | $8 | $16 |
| ម៉ាកដែលនិយមប្រើ | $25 | $50 |
| គ្មានចំណូលចិត្ត | $50 | $100 |

*ប្រសិនបើអ្នកធ្វើការឱ្យអង្គការដែលមានមូលដ្ឋានលើសាសនា គម្រោងសុខភាពរបស់អ្នកមិនរាប់បញ្ចូលការធានារ៉ាប់រងពន្យារកំណើត ដូចដែលបានអនុញ្ញាតស្របតាមករណីលើកលែងសាសនាក្នុង Affordable Care Act (ច្បាប់ថែទាំដែលមានតម្លៃសមរម្យ)។ ទោះជាយ៉ាងណាក៏ដោយ អ្នកនឹងទទួលបានសេវាទាំងនេះដោយមិនគិតថ្លៃសម្រាប់អ្នក (និងដោយមិនចាត់វិធានការបន្ថែមណាមួយ) ពី Kaiser Permanente ដរាបណាអ្នកបានចុះឈ្មោះក្នុងគម្រោងសុខភាព។
**ឱសថផ្អែកតាមតម្លៃជាឱសថទូទៅសម្រាប់ព្យាបាលស្ថានភាពសុខភាពផ្សេងៗ។

## គ្រប់គ្រងសុខភាពរបស់អ្នក

ស្ថានភាពជំងឺរ៉ាំរ៉ៃដូចជាជំងឺទឹកនោមផ្អែម ការឈឺចាប់រ៉ាំរ៉ៃ ឬជំងឺលើសឈាមអាចប៉ះពាល់ដល់គុណភាពជីវិតរបស់អ្នក ហើយត្រូវការការព្យាបាលពិសេស។ ជាសំណាងល្អ វាអាចត្រូវបានព្យាបាលបានយ៉ាងមានប្រសិទ្ធភាព តាមរយៈរបៀបរស់នៅដែលមានសុខភាពល្អ ការថែទាំបង្ការ និងការគ្រប់គ្រងបន្តបន្ទាប់។

បន្ថែមពីលើការទៅពិនិត្យថែទាំបឋមសម្រាប់ការថែទាំទូទៅ និងការបញ្ជូនបន្តរបស់អ្នកឯកទេស គម្រោងរបស់អ្នកក៏ផ្តល់ជូនផងដែរនូវ៖

**ការបណ្តុះបណ្តាលអំពីសុខភាព**សម្រាប់ការណែនាំដែលមានលក្ខណៈផ្ទាល់ខ្លួនដើម្បីទទួលបាន និងមានសុខភាពល្អ។

**កម្មវិធី និងការណែនាំ**ពីក្រុមអ្នកថែទាំដែលមានលក្ខណៈផ្ទាល់ខ្លួនដើម្បីជួយគ្រប់គ្រងស្ថានភាពរបស់អ្នក។

**កម្មវិធីស្មាតហ្វូន**សម្រាប់កម្មវិធីលំហាត់ប្រាណផ្ទាល់ខ្លួន សមាធិ ការប្រឹក្សា និងច្រើនទៀត។

ស្វែងយល់បន្ថែមនៅ **myseiu.be/oe-cc**។


Sandra C.
អ្នកថែទាំ, Kennewick

# សេចក្ដីសង្ខេបគម្រោង POS ជម្រើសធានារ៉ាប់រងដោយខ្លួនឯង

## កាលបរិច្ឆេទចូលជាធរមាននៅថ្ងៃទី 8/1/2024

នេះជាព័ត៌មានសង្ខេបអំពីអត្ថប្រយោជន៍។ នេះមិនមែនជាកិច្ចសន្យា ឬវិញ្ញាបនបត្របញ្ជាក់ការធានារ៉ាប់រងនោះទេ។ ការពណ៌នាអំពីអត្ថប្រយោជន៍ទាំងអស់ រួមទាំងការថែទាំជម្រើសផ្សេងទៀត គឺសម្រាប់សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ។ សមាជិកនឹងត្រូវបានគិតប្រាក់តិចជាងប្រាក់រួមចំណែកចំណាយសម្រាប់សេវាដែលមានធានារ៉ាប់រង ឬគិតថ្លៃជាក់ស្ដែងសម្រាប់សេវានោះ។ សម្រាប់បញ្ញត្តិស្ដីពីការធានារ៉ាប់រងពេញលេញ រួមទាំងដែនកំណត់ សូមមើលវិញ្ញាបនបត្របញ្ជាក់ការធានារ៉ាប់រងរបស់អ្នក។

| អត្ថប្រយោជន៍ | នៅក្នុងបណ្ដាញ | ក្រៅបណ្ដាញ |
|---|---|---|
| **ប្រាក់កាត់កងក្នុងគម្រោង** | គ្មានប្រាក់កាត់កងប្រចាំឆ្នាំ | ប្រាក់កាត់កងសម្រាប់បុគ្គល៖ $500 ក្នុងមួយឆ្នាំប្រតិទិន |
| **ការលើកប្រាក់កាត់កងសម្រាប់បុគ្គលទៅពេលក្រោយ** | មិនអាចអនុវត្តបាន | ប្រាក់បន្តនៅត្រីមាសទី 4 ត្រូវបានអនុវត្ត |
| **សហធានារ៉ាប់រងនៃគម្រោង** | គ្មានសហធានារ៉ាប់រងនៃគម្រោង | គម្រោងបង់ 80% អ្នកបង់ 20% នៃចំនួនទឹកប្រាក់ដែលបានអនុញ្ញាត។ |
| **ដែនកំណត់ប្រាក់ក្រៅហោប៉ៅ** | **ដែនកំណត់ប្រាក់ក្រៅហោប៉ៅនីមួយៗ៖** $1,200<br>ការចំណាយប្រាក់ក្រៅហោប៉ៅលើសេវាដែលរ៉ាប់រងខាងក្រោមត្រូវបានបញ្ចូលក្នុងដែនកំណត់ប្រាក់ក្រៅហោប៉ៅ៖<br>ប្រាក់រួមចំណែកថ្លៃចំណាយទាំងអស់សម្រាប់សេវាដែលមានការធានារ៉ាប់រង | ដែនកំណត់ប្រាក់ក្រៅហោប៉ៅបានរួមចំណែកជាមួយសេវាក្នុងបណ្ដាញ<br>ការចំណាយប្រាក់ក្រៅហោប៉ៅលើសេវាដែលរ៉ាប់រងខាងក្រោមត្រូវបានបញ្ចូលក្នុងដែនកំណត់ប្រាក់ក្រៅហោប៉ៅ៖<br>ប្រាក់រួមចំណែកថ្លៃចំណាយទាំងអស់សម្រាប់សេវាដែលមានការធានារ៉ាប់រង |
| **ចិរវេលារង់ចាំនៃស្ថានភាពដែលមានស្រាប់ពីមុន (PEC)** | គ្មាន PEC | ដូចគ្នានឹងបណ្ដាញ |
| **កម្រិតកំណត់ធានារ៉ាប់រង** | គ្មានដែនកំណត់ | ដូចគ្នានឹងអតិបរមាបណ្ដាញ |
| **សេវាសម្រាប់អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ (ការទៅជួបនៅការិយាល័យ)** | គ្មានប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការថែទាំបឋម/ ប្រាក់ចំណាយផ្ទាល់ខ្លួន $15 សម្រាប់ឯកទេស | ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវាមន្ទីរពេទ្យ** | **សេវាសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្ដង<br>**ការវះកាត់អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $50 | **សេវាសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្ដង។ ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**ការវះកាត់អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $50 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **ឱសថតាមវេជ្ជបញ្ជា** (ឱសថដែលអាចចាក់បានមួយចំនួនអាចត្រូវបានរ៉ាប់រងនៅក្រោមសេវាអ្នកជំងឺក្រៅ) | ឱសថដែលផ្អែកលើតម្លៃ/ទូទៅដែលនិយមប្រើ (កម្រិតទី 1)/ឱសថម៉ាកដែលនិយមប្រើ (កម្រិតទី 2)/មិននិយមប្រើ (កម្រិតទី 3) ប្រាក់ចំណាយផ្ទាល់ខ្លួន $4/$8/$25/$50 ក្នុងមួយការផ្គត់ផ្គង់ 30 ថ្ងៃ<br>អាំងស៊ុយលីន៖ ឱសថទូទៅដែលនិយមប្រើ (កម្រិតទី 1)/ម៉ាកដែលនិយមប្រើ (កម្រិតទី 2)/ដែលមិននិយមប្រើ (កម្រិតទី 3) $0/$0/$25 | ម៉ាកទូទៅ/ម៉ាកដែលនិយមប្រើ/មិននិយមប្រើ<br>ប្រាក់ចំណាយផ្ទាល់ខ្លួន $13/$30/$55 ក្នុងការផ្គត់ផ្គង់ 30 ថ្ងៃ<br>អាំងស៊ុយលីន៖ ឱសថទូទៅដែលនិយមប្រើ (កម្រិតទី 1)/ម៉ាកដែលនិយមប្រើ (កម្រិតទី 2)/ដែលមិននិយមប្រើ (កម្រិតទី 3) $0/$0/$25 |
| **ការបញ្ជាទិញតាមប្រៃសណីយ៍ដែលមានវេជ្ជបញ្ជា** | បញ្ចុះតម្លៃ $5 ក្នុងការផ្គត់ផ្គង់ 30 ថ្ងៃ | មិនត្រូវបានធានា |
| **ការចាក់ម្ជុលវិទ្យាសាស្ត្រ** | ធានារ៉ាប់រងលើការជួបពិគ្រោះរហូតដល់ 20 ដងក្នុងមួយការធ្វើរោគវិនិច្ឆ័យវេជ្ជសាស្ត្រក្នុងមួយឆ្នាំប្រតិទិនដោយគ្មានការអនុញ្ញាតជាមុន។ ការជួបពិគ្រោះបន្ថែមនៅពេលដែលបានអនុម័តដោយគម្រោង - ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវារថយន្តសង្គ្រោះបន្ទាន់** | គម្រោងបង់ 80% អ្នកបង់ 20% | ដូចគ្នានឹងបណ្ដាញ |
| **ភាពញៀនសារធាតុគីមី** | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្ដង<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្ដង ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |

| អត្ថប្រយោជន៍ | នៅក្នុងបណ្តាញ | ក្រៅបណ្តាញ |
|---|---|---|
| **ឧបករណ៍ បរិក្ខារ និងសម្ភារៈ**<br>• ឧបករណ៍ បរិក្ខារ និងសម្ភារៈ<br>• បរិក្ខារវេជ្ជសាស្ត្រប្រើជាប់យូរ<br>• គ្រឿងបរិក្ខារតម្រង់ឆ្អឹង<br>• អាវទ្រនាប់ក្រោយសម្រាលបានកំណត់ត្រឹមពីរ (2) រៀងរាល់ប្រាំមួយ (6) ខែ<br>• សម្ភារៈវះកាត់បើកផ្លូវចូលទៅក្នុងពោះវៀនធំ<br>• ឧបករណ៍សិប្បនិម្មិត | ត្រូវបានធានាត្រឹម 100%។ តម្រូវឱ្យមានការអនុញ្ញាតជាមុន បើពុំនោះទេនឹងមិនត្រូវបានធានារ៉ាប់រងឡើយ។ | ត្រូវបានធានាត្រឹម 50% ប្រាក់បង់មុនត្រូវបានអនុវត្ត |
| **សម្ភារៈជំងឺទឹកនោមផ្អែម** | អាំងស៊ុយលីន ម្ជុល សឺរ៉ាំង និងប្រដាប់ជោះ - សូមមើលឱសថតាមវេជ្ជបញ្ជា។ ម៉ាស៊ីនបូមអាំងស៊ុយលីនខាងក្រៅ ឧបករណ៍ត្រួតពិនិត្យគ្លុយកូសក្នុងឈាម សារធាតុធ្វើតេស្ត និងសម្ភារៈ សូមមើលឧបករណ៍ បរិក្ខារ និងសម្ភារៈ។ នៅពេលដែលឧបករណ៍ សម្ភារៈ និងបរិក្ខារ ឬឱសថតាមវេជ្ជបញ្ជាត្រូវបានរ៉ាប់រង និងមានដែនកំណត់អត្ថប្រយោជន៍ សម្ភារៈជំងឺទឹកនោមផ្អែមមិនស្ថិតក្រោមដែនកំណត់ទាំងនេះទេ។ | អាំងស៊ុយលីន ម្ជុល សឺរ៉ាំង និងប្រដាប់ជោះ - សូមមើលឱសថតាមវេជ្ជបញ្ជា។ ម៉ាស៊ីនបូមអាំងស៊ុយលីនខាងក្រៅ ឧបករណ៍ត្រួតពិនិត្យគ្លុយកូសក្នុងឈាម សារធាតុធ្វើតេស្ត និងសម្ភារៈ សូមមើលឧបករណ៍ បរិក្ខារ និងសម្ភារៈ។ នៅពេលដែលឧបករណ៍ សម្ភារៈ និងបរិក្ខារ ឬឱសថតាមវេជ្ជបញ្ជាត្រូវបានរ៉ាប់រង និងមានដែនកំណត់អត្ថប្រយោជន៍ សម្ភារៈជំងឺទឹកនោមផ្អែមមិនស្ថិតក្រោមដែនកំណត់ទាំងនេះទេ។ |
| **សេវាមន្ទីរពិសោធន៍រោគវិនិច្ឆ័យ និងកាំរស្មីអ៊ិច** | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ត្រូវបានធានាក្រោមសេវាមន្ទីរពេទ្យ<br>អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖ ធានារ៉ាប់រងពេញលេញ<br>**សេវាថតឆ្លុះ** រូបភាពវិទ្យុសកម្មទំនើបដូចជា CT, MR និង PET ត្រូវតែកំណត់ថាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ហើយតម្រូវឱ្យមានការអនុញ្ញាតជាមុន លើកលែងតែនៅពេលដែលមានទំនាក់ទំនងជាមួយសេវាសង្គ្រោះបន្ទាន់ ឬសេវាអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ។ | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ត្រូវបានធានាក្រោមសេវាមន្ទីរពេទ្យ<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>សេវាថតឆ្លុះរូបភាពវិទ្យុសកម្មទំនើបដូចជា CT, MR និង PET ត្រូវតែកំណត់ថាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ហើយតម្រូវឱ្យមានការអនុញ្ញាតជាមុន លើកលែងតែនៅពេលដែលមានទំនាក់ទំនងជាមួយសេវាសង្គ្រោះបន្ទាន់ ឬសេវាអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ។ |
| **សេវាសង្គ្រោះបន្ទាន់**<br>(ប្រាក់ចំណាយផ្ទាល់ខ្លួនត្រូវបានលើកលែង ប្រសិនបើអនុញ្ញាតឱ្យចូលសម្រាក) | ប្រាក់ចំណាយផ្ទាល់ខ្លួន $200 | ប្រាក់ចំណាយផ្ទាល់ខ្លួន $200 |
| **ការពិនិត្យការស្តាប់ (តាមទម្លាប់)** | ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **ឧបករណ៍ជំនួយការស្តាប់** | ត្រូវបានធានាតាមរយៈអត្ថប្រយោជន៍ដាច់ដោយឡែកមួយ៖ ផ្នែកការស្តាប់ EPIC។ មិនមានការបង់ប្រាក់ចំណាយផ្ទាល់ខ្លួនទេ រហូតដល់ $3,000 សម្រាប់ត្រចៀកម្ខាងរៀងរាល់ 3 ឆ្នាំ គិតជាថ្លៃចំណាយលើប្រដាប់ជំនួយការស្តាប់។ ស្វែងយល់បន្ថែមនៅ myseiu.be/epic | ត្រូវបានធានាតាមរយៈអត្ថប្រយោជន៍ដាច់ដោយឡែកមួយ៖ ផ្នែកការស្តាប់ EPIC។ មិនមានការបង់ប្រាក់ចំណាយផ្ទាល់ខ្លួនទេ រហូតដល់ $3,000 សម្រាប់ត្រចៀកម្ខាងរៀងរាល់ 3 ឆ្នាំ គិតជាថ្លៃចំណាយលើប្រដាប់ជំនួយការស្តាប់។ ស្វែងយល់បន្ថែមនៅ myseiu.be/epic |
| **សេវាសុខាភិបាលនៅផ្ទះ** | ធានារ៉ាប់រងពេញលេញ។ គ្មានការកំណត់ចំពោះការជួបពិគ្រោះ។ | គ្មានដែនកំណត់សម្រាប់ការជួបពិគ្រោះ<br>ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវាថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ** | ធានារ៉ាប់រងពេញលេញ | ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវាព្យាបាលភាពមិនមានកូន** | ត្រូវបានធានាតាមរយៈអត្ថប្រយោជន៍ដាច់ដោយឡែកមួយ៖ ការមានកូន និងការកសាងគ្រួសារ Progyny។ 2+1 Smart Cycles ដើម្បីជួយសមាជិកតាមរយៈដំណើរនៃការមានកូន និងការកសាងគ្រួសាររបស់ពួកគេ។ ស្វែងយល់បន្ថែមនៅ myseiu.be/progyny | មិនត្រូវបានធានា |
| **ការព្យាបាលដោយចលនាដៃ** | ធានារ៉ាប់រងរហូតដល់ការជួបពិគ្រោះ 20 ដងក្នុងមួយឆ្នាំប្រតិទិនដោយគ្មានការអនុញ្ញាតជាមុន<br>ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | ដែនកំណត់ជួបពិគ្រោះដែលបានរួមចំណែកជាមួយសេវាក្នុងបណ្តាញ<br>ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវាម៉ាស្សា** | សូមមើលសេវាស្តារនីតិសម្បទាឡើងវិញ | សូមមើលសេវាស្តារនីតិសម្បទាឡើងវិញ |
| **សេវាសម្ភព** | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $0។ ការថែទាំតាមទម្លាប់ មិនមានការបង់ប្រាក់ចំណាយផ្ទាល់ខ្លួលលើសេវាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យទេ។ | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត។ ការថែទាំតាមទម្លាប់ មិនមានការបង់ប្រាក់ចំណាយផ្ទាល់ខ្លួលលើសេវាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យទេ។ |
| **សុខភាពផ្លូវចិត្ត** | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង<br>ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់កាត់កង និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |

| អត្ថប្រយោជន៍ | នៅក្នុងបណ្តាញ | ក្រៅបណ្តាញ |
|---|---|---|
| **ការព្យាបាលតាមបែបធម្មជាតិ** | ប្រាក់ចំណាយផ្ទាល់ខ្លួន $0។ ការជួបពិគ្រោះគ្មានដែនកំណត់ក្នុងមួយឆ្នាំប្រតិទិនដោយមិនទាមទារការអនុញ្ញាតជាមុន។ ធានារ៉ាប់រងពេញលេញ។ | ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវាទារកទើបនឹងកើត** | **ការស្នាក់នៅមន្ទីរពេទ្យដំបូង៖** សូមមើលសេវាមន្ទីរពេទ្យ; ការជួបពិគ្រោះនៅការិយាល័យ៖ សូមមើលសេវាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ ការថែទាំសុខភាពជាប្រចាំ៖ សូមមើលការថែទាំបង្ការ។<br>ការរួមចំណែកថ្លៃចំណាយដែលពាក់ព័ន្ធណាមួយលើសេវាទារកទើបនឹងកើតគឺដាច់ដោយឡែកពីម្តាយ។ | **ការស្នាក់នៅមន្ទីរពេទ្យដំបូង៖** សូមមើលសេវាមន្ទីរពេទ្យ; ការជួបពិគ្រោះនៅការិយាល័យ៖ សូមមើលសេវាអ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ ការថែទាំសុខភាពជាប្រចាំ៖ សូមមើលការថែទាំបង្ការ។<br>ការរួមចំណែកថ្លៃចំណាយដែលពាក់ព័ន្ធណាមួយលើសេវាទារកទើបនឹងកើតគឺដាច់ដោយឡែកពីម្តាយ។ |
| **សេវាទាក់ទងនឹងជំងឺធាត់** | រ៉ាប់រងលើការរួមចំណែកថ្លៃចំណាយនៅពេលដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យវេជ្ជសាស្ត្រ | រ៉ាប់រងលើការរួមចំណែកថ្លៃចំណាយនៅពេលដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យវេជ្ជសាស្ត្រ |
| **ការប្តូរសរីរាង្គ** | គ្មានដែនកំណត់ គ្មានរយៈពេលរង់ចាំ<br>អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖ ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង<br>អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖ ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | រួមចំណែកជាមួយសេវាក្នុងបណ្តាញ<br>អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖ ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖ ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **ការថែទាំបង្ការ**<br>**ការថែទាំរាងកាយឱ្យបានល្អ ការចាក់ថ្នាំបង្ការ ការពិនិត្យដោយកៀសមាត់ស្បូន (ភេប ស្មៀ) ការថតឆ្លុះមើលសុដន់** | ធានារ៉ាប់រងពេញលេញ<br>សេវាថែទាំបង្ការសម្រាប់ស្ត្រី (រួមទាំងថ្នាំពន្យារកំណើត និងឧបករណ៍ពន្យារកំណើត និងការក្រៀវ) ត្រូវបានធានារ៉ាប់រងទាំងស្រុង។ | ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>សេវាថែទាំបង្ការសម្រាប់ស្ត្រី (រួមទាំងថ្នាំពន្យារកំណើត និងឧបករណ៍ពន្យារកំណើត និងការក្រៀវ) ស្ថិតក្រោមការរួមចំណែកថ្លៃចំណាយលើការថែទាំបង្ការដែលពាក់ព័ន្ធ និងកម្រិតអតិបរមាអត្ថប្រយោជន៍។ ការថតឆ្លុះមើលសុដន់ជាប្រចាំ៖ ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **សេវាស្តារនីតិសម្បទាឡើងវិញ**<br>**ការទៅពិនិត្យស្តារនីតិសម្បទាឡើងវិញគឺជាចំនួនសរុបនៃការទៅព្យាបាលរួមគ្នាក្នុងមួយឆ្នាំប្រតិទិន** | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** 60 ថ្ងៃក្នុងមួយឆ្នាំប្រតិទិន។ សេវាដែលមានការវិនិច្ឆ័យសុខភាពផ្លូវចិត្តត្រូវបានរ៉ាប់រងដោយគ្មានដែនកំណត់។ ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ការជួបពិគ្រោះ 60 ដងក្នុងមួយឆ្នាំប្រតិទិន។ សេវាដែលមានការវិនិច្ឆ័យសុខភាពផ្លូវចិត្តត្រូវបានរ៉ាប់រងដោយគ្មានដែនកំណត់។ គ្មានប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការថែទាំបឋម/ ប្រាក់ចំណាយផ្ទាល់ខ្លួន $15 សម្រាប់ឯកទេស | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ចំនួនកំណត់នៃថ្ងៃដែលរួមចំណែកជាមួយប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងបណ្តាញក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ចំនួនកំណត់នៃការជួបពិនិត្យដែលបានរួមចំណែកជាមួយប្រាក់ចំណាយផ្ទាល់ខ្លួន $15 ក្នុងបណ្តាញ ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **កន្លែងថែទាំមានជំនាញ** | ធានារ៉ាប់រងពេញលេញរហូតដល់ 60 ថ្ងៃក្នុងមួយឆ្នាំប្រតិទិន | ដែនកំណត់ថ្ងៃដែលបានរួមចំណែកជាមួយអត្ថប្រយោជន៍ក្នុងបណ្តាញ ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **ការការពារកុំឱ្យមានកូន**<br>(ការកាត់បំពង់បង្ហូរទឹកនោម ការភ្ជាប់បំពង់) | ធានារ៉ាប់រងពេញលេញ។ | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត នីតិវិធីវះកាត់ការពារកុំឱ្យមានកូនរបស់ស្ត្រីត្រូវរ៉ាប់រងក្រោមការចំណាយថ្លៃចំណាយលើការថែទាំបង្ការដែលពាក់ព័ន្ធ និងកម្រិតអតិបរមានៃអត្ថប្រយោជន៍។ |
| **សេវាផ្នែកសន្លាក់**<br>**Temporomandibular Joint (TMJ)** | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | **អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $100 ក្នុងមួយថ្ងៃរហូតដល់ 5 ថ្ងៃសម្រាប់ការចូលសម្រាកម្តង ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត<br>**អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ៖** ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **ការប្រឹក្សាអំពីការឈប់ជក់ថ្នាំជក់** | កម្មវិធី Quit for Life Program - ធានារ៉ាប់រងទាំងស្រុង | ការរួមចំណែកថ្លៃចំណាយត្រូវបានអនុវត្ត |
| **ការថែទាំភ្នែកជាប្រចាំ**<br>(ការជួបពិគ្រោះ 1 ដងរៀងរាល់ 12 ខែ) | ប្រាក់ចំណាយផ្ទាល់ខ្លួន $0 | ប្រាក់ចំណាយផ្ទាល់ខ្លួន $15 ប្រាក់បង់មុន និងសហធានារ៉ាប់រងត្រូវបានអនុវត្ត |
| **ឧបករណ៍អុបទិក**<br>**កញ្ចក់លែន រួមទាំងកញ្ចក់ពាក់កែវភ្នែក និងស៊ុម** | **សមាជិកអាយុក្រោម 19 ឆ្នាំ៖** ស៊ុម និងកញ្ចក់លែន 1 គូក្នុងមួយឆ្នាំ ឬកញ្ចក់ពាក់កែវភ្នែកធានារ៉ាប់រងដោយមានសហធានារ៉ាប់រង 50%<br>**សមាជិកដែលមានអាយុចាប់ពី 19 ឆ្នាំឡើងទៅ៖** $600 ក្នុងរយៈពេល 12 ខែម្តង | រួមចំណែកជាមួយសេវាក្នុងបណ្តាញ |




ថ្មី!

progyny

# អត្ថប្រយោជន៍នៃការមានកូន និងការកសាងគ្រួសារ

## ទទួលបានអត្ថប្រយោជន៍សម្រាប់គ្រប់ដំណាក់កាលនៃជីវិត ចាប់ពីការមានកូន និងការកសាងគ្រួសារ រហូតដល់មានផ្ទៃពោះ ក្រោយសម្រាល និងអស់រដូវ។

**អត្ថប្រយោជន៍នៃការមានកូនដែលត្រូវបានធ្វើឱ្យប្រសើរឡើងឥឡូវនេះមានសម្រាប់អ្នកតាមរយៈ Progyny។**

Progyny ផ្តល់ការរ៉ាប់រងសម្រាប់ការព្យាបាលចុងក្រោយបំផុត ការគាំទ្រ និងការណែនាំដែលមានលក្ខណៈផ្ទាល់ខ្លួនពីអ្នកគាំទ្រផ្នែកថែទាំអ្នកជំងឺ (PCA) ឯកទេស និងការទទួលបានការថែទាំដោយផ្ទាល់ និងតាមបណ្តាញអ៊ីនធឺណិតប្រកបដោយគុណភាពខ្ពស់។

PCA គឺជាចំណុចអន្តរកម្មទីមួយនៃដំណើរកសាងគ្រួសាររបស់អ្នក។ ពួកគេនឹងណែនាំអ្នកតាមរយៈដំណើរទាំងស្រុងនៃការមានកូនរបស់អ្នក ការកសាងគ្រួសារ ឬដំណើរអស់រដូវរបស់អ្នក ដោយផ្តល់ការអប់រំអំពីកម្មវិធីដែលមាន ជម្រើសនៃការព្យាបាល ការសម្របសម្រួលការថែទាំ និងការគាំទ្រដោយយកចិត្តទុកដាក់។

បន្ថែមពីលើការគាំទ្រ PCA អ្នកមានសិទ្ធិចូលប្រើវិបផតថល និងកម្មវិធីរបស់សមាជិក Progyny ដែលអ្នកអាចមើលព័ត៌មានលម្អិតអំពីការធានារ៉ាប់រង ពិនិត្យមើលការណាត់ជួបនាពេលខាងមុខ ប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយ PCA របស់អ្នក និងទទួលបានការអប់រំនៃការមានកូន និងការកសាងគ្រួសារ។

## ការថែទាំសុខភាពមុនពេលមានផ្ទៃពោះ និងការគាំទ្រ

ការចាប់ផ្តើមគិតអំពីការកសាងគ្រួសារអាចឱ្យអ្នកមានអារម្មណ៍ក្កកក្ដួល។ តាមរយៈ Progyny អ្នកអាចចូលប្រើកម្មវិធីរយៈពេល 12 ខែសម្រាប់ការគាំទ្រដែលមានលក្ខណៈផ្ទាល់ខ្លួន ការអប់រំ និងធនធានសម្រាប់ការមានផ្ទៃពោះដែលមានសុខភាពល្អ និងទារកដែលសប្បាយរីករាយ។

## ការមានកូន និងការកសាងគ្រួសារ

មិនថាអ្នកចង់ស្វែងយល់បន្ថែមអំពីការរក្សាការមានកូន កំពុងតែព្យាយាមមានគភ៌ ឬកំពុងស្វែងរកការព្យាបាលការមានកូនទេ Progyny អាចទ្រទ្រង់អ្នកគ្រប់ជំហាននៃមធ្យោបាយជាមួយ៖

- ភាពងាយស្រួលចូលទៅកាន់បណ្ដាញអ្នកឯកទេសខាងការមានកូន។
- ការគាំទ្រផ្នែកព្យាបាល និងជំនួយគាំទ្រផ្លូវអារម្មណ៍គ្មានដែនកំណត់ពី PCA ឯកទេស។
- រាល់សេវាកម្ម ការធ្វើតេស្ត និងការព្យាបាលនីមួយៗទាំអស់ដែលអ្នកប្រហែលជាត្រូវការ។

## ការថែទាំពេលអស់រដូវ និងពាក់កណ្ដាលជីវិត

ទទួលបានការថែទាំតាមបណ្ដាញអ៊ីនធឺណិតនៅគ្រប់ដំណាក់កាលនៃការអស់រដូវជាមួយនឹងបណ្ដាញរបស់ Progyny នៃគ្រូពេទ្យ អ្នកឯកទេសខាងចំណីអាហារ និងគិលានុបដ្ឋាយិកាដែលមានការទទួលស្គាល់។ បន្ទាប់ពីការវាយតម្លៃដំបូង អ្នកនឹងទទួលបានផែនការថែទាំដែលមានលក្ខណៈផ្ទាល់ខ្លួនដែលប្រើប្រាស់ការរួមបញ្ចូលគ្នានេះ៖

- អាហារបំប៉នដែលមិនមែនជាអរម៉ូន និងថ្នាំអរម៉ូន។
- ការគាំទ្ររបៀបរស់នៅសម្រាប់អាហាររូបត្ថម្ភ ទម្ងន់ ការគេង និងសុខភាពផ្លូវអារម្មណ៍។
- ការពិនិត្យរកមើលហានិភ័យសុខភាពទាក់ទងនឹងអាយុ។ អ្នកអាចបន្តទទួលបានការបើកថ្នាំ និងជំនួយតាមតម្រូវការ ដរាបណាអ្នកត្រូវការ។

## ដំណើរផ្លាស់ប្ដូរការថែទាំ

ប្រសិនបើអ្នកកំពុងទទួលការព្យាបាលការមានកូនតាមរយៈគម្រោងសុខភាពរបស់អ្នក ហើយការព្យាបាលរបស់អ្នកនឹងមិនត្រូវបានបញ្ចប់នៅចុងឆ្នាំនៃផែនការ (ថ្ងៃទី 31 ខែកក្កដា ឆ្នាំ 2024) នោះ Progyny ផ្ដល់ដំណើរផ្លាស់ប្ដូរនៃការសម្របសម្រួលការថែទាំដើម្បីផ្ដល់ការគាំទ្របន្តនៅក្នុងដំណើរមានកូន និងកសាងគ្រួសាររបស់អ្នក។

សូមទូរសព្ទទៅលេខ **1-833-233-0517** ដើម្បីនិយាយជាមួយ PCA ដែលនឹងអាចជួយអ្នកក្នុងការផ្លាស់ប្ដូរដំណើរការថែទាំ និងធានាថាមិនមានការរំខានក្នុងការថែទាំ។

## ស្វែងយល់បន្ថែម ឬចាប់ផ្ដើមប្រើប្រាស់អត្ថប្រយោជន៍របស់អ្នកដោយទូរសព្ទទៅលេខ **1-833-233-0517**

អ្នកថែទាំដែលបានចុះឈ្មោះក្នុងការធានារ៉ាប់រងសុខភាពអាចទទួលបានអត្ថប្រយោជន៍នេះចាប់ពីថ្ងៃទី 1 ខែសីហា ឆ្នាំ 2024។



Sandra C.
អ្នកថែទាំ, Kennewick

# សេចក្តីសង្ខេបនៃអត្ថប្រយោជន៍ និងការធានារ៉ាប់រង

**រយៈពេលធានារ៉ាប់រង៖ 08/01/2024 – 07/31/2025**

ឯកសារនៃសេចក្តីសង្ខេបនៃអត្ថប្រយោជន៍ និងការធានារ៉ាប់រង (SBC) នឹងជួយអ្នកជ្រើសរើសគម្រោងសុខភាព។ SBC បង្ហាញអ្នកពីរបៀបដែលអ្នក និងផែនការនឹងចូលរួមចំណែកក្នុងការចំណាយសម្រាប់សេវាថែទាំសុខភាពដែលត្រូវបានធានារ៉ាប់រង។ នេះគ្រាន់តែជាការសង្ខេបប៉ុណ្ណោះ។ ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីការធានារ៉ាប់រងរបស់អ្នក សូមទាក់ទងអ្នកគាំទ្រការថែទាំអ្នកជំងឺ (PCA) Progyny របស់អ្នកតាមរយៈលេខ (833) 233-0517។

| សំណួរសំខាន់ៗ | ចម្លើយ | ហេតុអ្វីបានជាវាមានសារៈសំខាន់៖ |
|---|---|---|
| **តើប្រាក់ចំណាយដែលត្រូវបង់ជាមុនសរុបមានចំនួនប៉ុន្មាន?** | **លក្ខណៈបុគ្គល $0 / គ្រួសារ $0** | មិនមានប្រាក់ចំណាយដែលត្រូវបង់ជាមុនជាមួយគម្រោង Progyny របស់អ្នកទេ។ |
| **តើខ្ញុំមានប្រាក់ចំណាយផ្ទាល់ខ្លួនដែរឬទេ?** | ទេ | មិនមានសហធានារ៉ាប់រងជាមួយគម្រោង Progyny របស់អ្នកទេ។ |
| **តើខ្ញុំមានសហធានារ៉ាប់រងដែរឬទេ?** | ទេ | មិនមានសហធានារ៉ាប់រងជាមួយគម្រោង Progyny របស់អ្នកទេ។ |
| **តើមានសេវាដែលត្រូវបានរ៉ាប់រងមុនពេលអ្នកបំពេញប្រាក់ចំណាយដែលត្រូវបង់ជាមុនរបស់អ្នកដែរឬទេ?** | ទេ | អ្នកនឹងបង់លុយចេញពីហោប៉ៅសម្រាប់សេវាផ្នែកមានកូនដែលមានសិទ្ធិរបស់អ្នករហូតដល់អ្នកឈានដល់ប្រាក់ចំណាយដែលត្រូវបង់ជាមុន $0 ប្រចាំឆ្នាំក្នុងមនុស្សម្នាក់។ |
| **តើមានប្រាក់ចំណាយដែលត្រូវបង់ជាមុនផ្សេងទៀតសម្រាប់សេវាកម្មជាក់លាក់ដែរឬទេ?** | ទេ | មានតែប្រាក់ចំណាយដែលត្រូវបង់ជាមុនដែលតម្រូវសម្រាប់គម្រោង Progyny HRA ប៉ុណ្ណោះ។ |
| **តើដែនកំណត់ប្រាក់ចេញពីហោប៉ៅសម្រាប់ផែនការនេះមានចំនួនប៉ុន្មាន?** | លក្ខណៈបុគ្គល $0 / គ្រួសារ $0 | មិនមានដែនកំណត់ចេញពីហោប៉ៅជាមួយគម្រោង Progyny របស់អ្នកទេ។ |
| **តើអ្នកនឹងចំណាយកាន់តែតិចឬ ប្រសិនបើអ្នកប្រើអ្នកផ្តល់សេវាក្នុងបណ្តាញ?** | មិនអាចអនុវត្តបាន។ | អ្នកផ្តល់សេវាក្នុងបណ្តាញនៃមជ្ឈមណ្ឌលឧត្តមភាពរបស់ Progyny ត្រូវបានរួមបញ្ចូលទាំងអស់នៅក្នុងផែនការនេះ។ អ្នកត្រូវតែប្រើអ្នកផ្តល់សេវាក្នុងបណ្តាញ។ |

**សេវាកម្មដែលមិនរាប់បញ្ចូល និងសេវាដែលត្រូវបានរ៉ាប់រងផ្សេងទៀត៖**
ការមិនរាប់បញ្ចូលរួមមានឧបករណ៍ព្យាករណ៍ការបញ្ចេញពងអូវុលប្រើប្រាស់នៅផ្ទះ សេវាកម្ម និងបរិក្ខារដែលផ្តល់ដោយអ្នកផ្តល់សេវាក្រៅបណ្តាញនិងការព្យាបាលដែលត្រូវបានចាត់ទុកថាជាការពិសោធន៍ដោយ American Society of Reproductive Medicine (សមាគមឱសថបន្តពូជរបស់អាមេរិក)។ ការគិតថ្លៃទាំងអស់ដែលទាក់ទងនឹងសេវាកម្មសម្រាប់អ្នកពពោះជំនួស រួមមានជាអាទិ៍ ថ្លៃសេវាសម្រាប់ការធ្វើតេស្តមន្ទីរពិសោធន៍ មិនត្រូវបានរ៉ាប់រងទេ។ ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកស្នើសុំសេវាកម្មដែលមិនមាននៅក្នុងមគ្គុទេសក៍នេះ សូមពិគ្រោះជាមួយ PCA របស់អ្នកដើម្បីបញ្ជាក់ការធានារ៉ាប់រង។ មានសេវាកម្មមួយចំនួនដែលមិនស្ថិតនៅក្រោមការធានារ៉ាប់រងរបស់ Progyny។ ទោះយ៉ាងណាក៏ដោយពួកគេអាចត្រូវបានផ្តល់ជូនតាមរយៈគម្រោងវេជ្ជសាស្ត្ររបស់អ្នក។

**សិទ្ធិរបស់អ្នកក្នុងការបន្តការធានារ៉ាប់រង៖**
មានទីភ្នាក់ងារដែលអាចជួយបាន ប្រសិនបើអ្នកចង់បន្តការធានារ៉ាប់រងរបស់អ្នកបន្ទាប់ពីវាបញ្ចប់។ ព័ត៌មានទំនាក់ទំនងសម្រាប់ទីភ្នាក់ងារទាំងនោះគឺ៖ Healthcare.gov៖ www.HealthCare.gov ឬទូរសព្ទទៅលេខ 1-800-318-2596 ឬទីផ្សារធានារ៉ាប់រងសុខភាពរបស់រដ្ឋ ឬ SHOP។ ជម្រើសនៃការធានារ៉ាប់រងផ្សេងទៀតអាចមានផ្តល់ជូនអ្នកផងដែរ រួមទាំងការទិញការធានារ៉ាប់រងលក្ខណៈបុគ្គលតាមរយៈទីផ្សារធានារ៉ាប់រងសុខភាព។ សម្រាប់ព័ត៌មានបន្ថែមអំពីទីផ្សារ សូមចូលទៅកាន់គេហទំព័រ www.HealthCare.gov ឬទូរសព្ទទៅលេខ 1-800-318- 2596។

**សិទ្ធិបណ្តឹងសារទុក្ខ និងបណ្តឹងឧទ្ធរណ៍របស់អ្នក៖**
មានទីភ្នាក់ងារដែលអាចជួយបាន ប្រសិនបើអ្នកមានបណ្តឹងប្រឆាំងនឹងផែនការរបស់អ្នកសម្រាប់ការបដិសេធការទាមទារសំណង។ បណ្តឹងនេះត្រូវបានគេហៅថា បណ្តឹងសារទុក្ខ ឬបណ្តឹងឧទ្ធរណ៍។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នក សូមមើលការពន្យល់អំពីអត្ថប្រយោជន៍ដែលអ្នកនឹងទទួលបានសម្រាប់ការទាមទារសំណងផ្នែកវេជ្ជសាស្ត្រនោះ។ ឯកសារគម្រោងរបស់អ្នកក៏ផ្តល់ព័ត៌មានពេញលេញអំពីរបៀបដាក់ពាក្យបណ្តឹងទាមទារ បណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសារទុក្ខសម្រាប់ហេតុផលណាមួយចំពោះគម្រោងរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិរបស់អ្នក ការជូនដំណឹងនេះ ឬជំនួយ សូមចូលទៅកាន់គេហទំព័រ www.dol.gov/ebsa/healthreform និង http://www.cms.gov/CCIIO/Resources/Consumer-Assistance-Grants។

**តើផែនការនេះផ្តល់ការធានារ៉ាប់រងចាំបាច់អប្បបរមា (Minimum Essential Coverage) ដែរឬទេ? មិនអាចអនុវត្តបាន។**
ការធានារ៉ាប់រងចាំបាច់អប្បបរមា (Minimum Essential Coverage) ជាទូទៅរួមបញ្ចូលនូវផែនការ ការធានារ៉ាប់រងសុខភាពដែលមានតាមរយៈទីផ្សារ ឬគោលនយោបាយទីផ្សារនីមួយៗផ្សេងទៀត Medicare, Medicaid, CHIP, TRICARE និងការធានារ៉ាប់រងមួយចំនួនផ្សេងទៀត។ ប្រសិនបើអ្នកមានសិទ្ធិទទួលបានប្រភេទមួយចំនួននៃការធានារ៉ាប់រងចាំបាច់អប្បបរមា (Minimum Essential Coverage) អ្នកប្រហែលជាមិនមានសិទ្ធិទទួលបានឥណទានពន្ធបុព្វលាភនោះទេ។

**តើផែនការនេះបំពេញតាមស្តង់ដារតម្លៃអប្បបរមាទេ? មិនអាចអនុវត្តបាន។**
ប្រសិនបើគម្រោងរបស់អ្នកមិនបំពេញតាមស្តង់ដារតម្លៃអប្បបរមា អ្នកអាចមានសិទ្ធិទទួលបានឥណទានពន្ធបុព្វលាភដើម្បីជួយអ្នកក្នុងការទូទាត់សម្រាប់គម្រោងតាមរយៈទីផ្សារ។

# ជម្រើសគម្រោងសុខភាពធ្មេញ

ប្រៀបធៀបគម្រោងសុខភាពធ្មេញ និង ជ្រើសរើសមួយដែលល្អបំផុតសម្រាប់អ្នក។



Amy L.
អ្នកថែទាំ, Seattle

## ធានារ៉ាប់រងសុខភាពធ្មេញត្រូវបានរួមបញ្ចូលនៅក្នុងប្រាក់កាត់កងនៃសហប្រុព្វលាភប្រចាំខែ $25 របស់អ្នក។

ប្រើតារាងខាងក្រោម ហើយពិនិត្យមើលព័ត៌មានសង្ខេបអត្ថប្រយោជន៍ផែនការ ដើម្បីជួយអ្នកប្រៀបធៀបផែនការ និងយល់ពីការចំណាយប្រាក់ហោប៉ៅដែលអាចកើតមានរបស់អ្នក។ ប្រសិនបើអ្នកបានចុះឈ្មោះរួចហើយក្នុងធានារ៉ាប់រង ហើយចង់ប្តូរគម្រោងសុខភាពធ្មេញរបស់អ្នក សូមដាក់បញ្ជូនពាក្យស្នើសុំរបស់អ្នកឱ្យបានត្រឹមថ្ងៃទី 20 ខែកក្កដា។

| | DELTA DENTAL | Willamette Dental Group |
|---|---|---|
| **អត្ថប្រយោជន៍អតិបរមាប្រចាំឆ្នាំ** | **$5,000** | **គ្មាន** |
| **ប្រាក់បង់មុន** | **$0** | **$0** |
| **ការពិនិត្យតាមទម្លាប់** | **ធានារ៉ាប់រងពេញលេញ** | **ធានារ៉ាប់រងពេញលេញ** |
| **អត្ថប្រយោជន៍នៃការតម្រង់ធ្មេញ** | **បាទ/ចាស** | **បាទ/ចាស** |
| **បណ្ដាញអ្នកផ្ដល់សេវាព្យាបាល** | Delta Dental មានបណ្ដាញអ្នកផ្ដល់សេវាទូលំទូលាយ រួមទាំងនៅតំបន់ជនបទផងដែរ។ អ្នកនឹងចង់ស្វែងរក ទន្តពេទ្យ Delta Dental ដើម្បីបង្កើនអត្ថប្រយោជន៍របស់អ្នក។ | Willamette Dental មានទីតាំងងាយស្រួលជាច្រើននៅ Washington ភាគខាងលិច ដែលអាចឱ្យអ្នកងាយស្រួលស្វែងរកទន្តពេទ្យ Willamette ប្រសិនបើអ្នករស់នៅតាមច្រករបៀង I-5។ |
| **ស្វែងរកពេទ្យធ្មេញនៅជិតអ្នក** | ចូលទៅកាន់ **deltadentalwa.com/fad/search** ហើយជ្រើសរើស “Delta Dental PPO” ដើម្បីច្រោះលទ្ធផលស្វែងរករបស់អ្នក។ | ចូលទៅកាន់ **locations.willamettedental.com** ហើយបញ្ចូលលេខកូដ ZIP របស់អ្នកទៅក្នុងរបារស្វែងរក។ |
| **សម្រាប់សំណួរ ឬព័ត៌មានបន្ថែម** | **1-800-554-1907**<br>**DeltaDentalWA.com** | **1-855-433-6825**<br>**myseiu.be/oe-willamette** |

DELTA DENTAL®

## គម្រោង PPO

### កាលបរិច្ឆេទចូលជាធរមាននៅថ្ងៃទី 8/1/2024

នេះជាការសង្ខេបខ្លីអំពីអត្ថប្រយោជន៍ដែលអាចប្រើប្រាស់បានសម្រាប់ជាការប្រៀបធៀបតែប៉ុណ្ណោះ ហើយវាមិនមែនជាកិច្ចសន្យាទេ។ ក្រោយពេលចុះឈ្មោះចូលគម្រោងរួច អ្នកនឹងមានសិទ្ធិចូលមើលកូនសៀវភៅស្ដីពីអត្ថប្រយោជន៍របស់អ្នក ដែលប្រាប់អ្នកអំពីព័ត៌មានលម្អិតនៃគម្រោង Delta Dental PPO របស់អ្នក។ ហៅទូរសព្ទទៅផ្នែកសេវាបម្រើអតិថិជន Delta Dental តាមរយៈលេខ **1-800-554-1907** ឬចូលទៅកាន់ **DeltaDentalWA.com** ប្រសិនបើអ្នកមានសំណួរណាមួយ។

**រយៈពេលអត្ថប្រយោជន៍៖**
**1/1/2025-12/31/2025**

**រយៈពេលអត្ថប្រយោជន៍អតិបរមា* (ក្នុងមនុស្សម្នាក់ មិនអនុវត្តចំពោះថ្នាក់ I)៖** $5,000

**ការព្យាបាលបញ្ហាធ្មេញនិងថ្គាម- មនុស្សពេញវ័យ និងកុមារ៖** 50% ដែលមានកម្រិតកំណត់ធានារ៉ាប់រង $5,000 ក្នុងមនុស្សម្នាក់

*ការថែទាំធ្មេញដែលបានទទួលនៅទន្តពេទ្យ PDA នឹងត្រូវបានរ៉ាប់រងពេញលេញរហូតដល់កម្រិតអតិបរមា $2,000 ដោយមានការលើកលែងសហធានារ៉ាប់រងជាមួយនឹងថ្នាក់ទី III - សេវាសំខាន់ៗ។

| | Delta Dental PPO | Delta Dental Premier | ក្រៅបណ្ដាញ |
|---|---|---|---|
| **ប្រាក់បង់មុនក្នុងរយៈពេលទទួលអត្ថប្រយោជន៍** | | | |
| មិនអនុវត្តចំពោះថ្នាក់ I និងការកែតម្រង់ធ្មេញ ក្រៅបណ្ដាញ ($50 ក្នុងមនុស្សម្នាក់) | $0 | $50 | $50 |
| **ថ្នាក់ទី 1- រោគវិនិច្ឆ័យ និងបង្ការ** | | | |
| ការពិនិត្យ<br>ការសម្អាត<br>ផ្លូអូរ៉ាយ<br>ការថតកាំរស្មីអ៊ិច<br>ប៉ះភ្ជិត | 100% | 80% | 80% |
| **ថ្នាក់ទី II - ស្ដារឡើងវិញ** | | | |
| ការបិទប៉ះធ្មេញ<br>ការប៉ះកុំប៉ូស៊ីតលើធ្មេញផ្នែកខាងក្រោយ<br>រោគបណ្ដូលធ្មេញ (ប្រហោងក្នុងធ្មេញ)<br>រោគអញ្ចាញធ្មេញ<br>ការវះកាត់ក្នុងមាត់ | 100% | 60% | 60% |
| **ថ្នាក់ទី III - ទ្រង់ទ្រាយធំ** | | | |
| ក្រាសធ្មេញពាក់<br>ក្រាសធ្មេញពាក់មួយផ្នែក<br>ដាំបង្គោលធ្មេញ<br>អបធ្មេញ<br>ស្រោបធ្មេញ | 80% | 40% | 40% |

| **លក្ខណៈពិសេស** | | | |
|---|---|---|---|
| ចំណាយប្រាក់ហោប៉ៅតិចបំផុត | ○ | | |
| ដាក់ពាក្យប្ដឹងទាមទារជំនួសឱ្យអ្នក | ○ | ○ | |
| ការគ្រប់គ្រងគុណភាព និងការការពារការចំណាយ | ○ | ○ | |

**ការសង្គ្រោះបន្ទាន់ផ្នែកធ្មេញ៖** អ្នកផ្ដល់សេវាដែលចូលរួមនឹងផ្ដល់ការព្យាបាលសម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកធ្មេញក្នុងអំឡុងពេលម៉ោងធ្វើការ។ ក្រុមហ៊ុននឹងផ្ដល់អត្ថប្រយោជន៍សម្រាប់សេវាដែលមានការធានារ៉ាប់រងដែលផ្ដល់ដោយអ្នកផ្ដល់សេវាដែលចូលរួមសម្រាប់ការព្យាបាលការសង្គ្រោះបន្ទាន់ផ្នែកធ្មេញ។ អ្នកចុះឈ្មោះអាចជួបព្យាបាលសម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកធ្មេញពីអ្នកផ្ដល់សេវាដែលមិនចូលរួម ប្រសិនបើអ្នកចុះឈ្មោះរស់នៅឆ្ងាយជាង 50 ម៉ាយល៍ពីការិយាល័យអ្នកផ្ដល់សេវាដែលចូលរួមណាមួយ។

## បណ្ដាញ Delta Dental

អត្ថប្រយោជន៍របស់អ្នកកាន់តែច្រើនបំផុតជាមួយបណ្ដាញ Delta Dental PPO។ អ្នកក៏អាចចូលទៅកាន់បណ្ដាញ Delta Dental Premier® ដែលជួយអ្នកពង្រីកជម្រើសរបស់អ្នកផងដែរ។

## ទទួលបានច្រាសដុសធ្មេញ Sonicare ឥតគិតថ្លៃ



សមាជិក Delta Dental ដែលទៅជួបអ្នកផ្ដល់សេវា Pacific Dental Alliance (PDA) ជាអ្នកជំងឺថ្មីអាចទទួលបានច្រាសដុសធ្មេញ Sonicare ដោយឥតគិតថ្លៃ។

មើលបញ្ជីឈ្មោះអ្នកផ្ដល់សេវា PDA ពេញលេញ៖ **myseiu.be/oe-pda**.

Willamette
Dental Group

# គម្រោងសុខភាពធ្មេញ

**កាលបរិច្ឆេទចូលជាធរមាននៅថ្ងៃទី 8/1/2024**

ធានាដោយ Willamette Dental of Washington, Inc. ផែនការនេះផ្តល់នូវការធានារ៉ាប់រងយ៉ាងទូលំទូលាយ។ បញ្ជីខាងក្រោមផ្តល់ព័ត៌មានសម្រាប់នីតិវិធីទូទៅមួយចំនួន ដែលមាននៅក្នុងគម្រោងរបស់អ្នក។ ទូរសព្ទទៅលេខ **1-855-433-6825** ឬចូលទៅកាន់ **myseiu.be/oe-willamette** សម្រាប់ព័ត៌មានបន្ថែម។ សម្រាប់បញ្ជីដាក់កម្រិតកំណត់ និងបញ្ជីលើកលែង សូមចូលទៅកាន់ **myseiu.be/willamette-exclusions**។

| អត្ថប្រយោជន៍ | ប្រាក់ចំណាយផ្ទាល់ខ្លួន |
|---|---|
| អតិបរមាប្រចាំឆ្នាំ | គ្មានអតិបរមាប្រចាំឆ្នាំ* |
| ប្រាក់បង់មុន | គ្មានប្រាក់បង់មុន |
| ការទៅពិនិត្យនៅការិយាល័យកែតម្រង់ធ្មេញ និងទូទៅ | គ្មានប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការជួបពិគ្រោះមួយលើក |
| **សេវាធ្វើតេស្តរោគវិនិច្ឆ័យ និងបង្ការ** | |
| ការពិនិត្យជាប្រចាំ និងសង្គ្រោះបន្ទាន់ ការថតកាំរស្មីអ៊ិច ការសម្អាតធ្មេញ ការព្យាបាលដោយហ្វ្លុយអូរីត ការប៉ះភ្ជិត (ក្នុងមួយធ្មេញ) ការពិនិត្យមហារីកក្បាល និងក ការណែនាំអំពីអនាម័យមាត់ធ្មេញ ការធ្វើតារាងចន្លោះធ្មេញ ការវាយតម្លៃចន្លោះធ្មេញ | ធានារ៉ាប់រងជាមួយ ប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការទៅពិនិត្យនៅការិយាល័យ |
| **ទន្តសាស្ត្រប៉ះបិទ** | |
| ការប៉ះធ្មេញ (Amalgam) | ធានារ៉ាប់រងជាមួយ ប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការទៅពិនិត្យនៅការិយាល័យ |
| ប៉សឺឡែន-ធ្មេញស្រោបដែក | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $250 |
| **ទន្តសាស្ត្រដាក់ធ្មេញសិប្បនិម្មិត** | |
| ធ្មេញស្និតខាងលើ ឬខាងក្រោមពេញ | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $400 |
| ការដាក់ធ្មេញស្ពាន (ក្នុងមួយធ្មេញ) | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $250 |
| **ផ្នែកបណ្តូលធ្មេញ និងអញ្ចាញធ្មេញ** | |
| ការព្យាបាលប្រហោងក្នុងធ្មេញ - ផ្នែកខាងមុខ | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $85 |
| ការព្យាបាលប្រហោងក្នុងធ្មេញ - Bicuspid | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $105 |
| ការព្យាបាលប្រហោងក្នុងធ្មេញ - Molar | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $130 |
| ការវះកាត់អញ្ចាញ (ក្នុងមួយបួនជ្រុង) | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $150 |
| ការដាំឫសធ្មេញ (ក្នុងមួយបួនជ្រុង) | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $75 |
| **ការវះកាត់ក្នុងមាត់** | |
| ការដកធ្មេញជាប្រចាំ (ធ្មេញតែមួយ) | ធានារ៉ាប់រងជាមួយ ប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការទៅពិនិត្យនៅការិយាល័យ |
| ការដកដោយវះកាត់ | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $100 |
| **ការព្យាបាលពត់តម្រង់ធ្មេញ** | |
| ការព្យាបាលពត់តម្រង់ធ្មេញជាមុន | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $150** |
| ការព្យាបាលធ្មេញទូលំទូលាយ | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $1,500 |
| **ការដាំបង្គោលធ្មេញ** | |
| ការវះកាត់ដាំបង្គោលធ្មេញ | កម្រិតកំណត់អត្ថប្រយោជន៍នៃការដាំបង្គោលចំនួន $1,500 ក្នុងមួយឆ្នាំប្រតិទិន |
| **ផ្សេងៗ** | |
| ការប្រើថ្នាំស្ពឹកលើកន្លែងដាក់លាក់ | ធានារ៉ាប់រងជាមួយ ប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការទៅពិនិត្យនៅការិយាល័យ |
| តម្លៃមន្ទីរពិសោធន៍ធ្មេញ | ធានារ៉ាប់រងជាមួយ ប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការទៅពិនិត្យនៅការិយាល័យ |
| Nitrous Oxide | អ្នកបង់ប្រាក់ចំណាយផ្ទាល់ខ្លួន $40 |
| ការទៅពិនិត្យនៅការិយាល័យឯកទេស | អ្នកបង់ប្រាក់ទូទាត់រួម $30 ក្នុងមួយលើក |
| ការទូទាត់សំណងលើការថែទាំសង្គ្រោះបន្ទាន់ក្រៅតំបន់ | អ្នកបង់ថ្លៃលើសពី $250 |

* TMJ មានចំនួនទឹកប្រាក់អតិបរមាប្រចាំឆ្នាំចំនួន $1000 / កម្រិតកំណត់ធានារ៉ាប់រង $5000 **ការបង់ប្រាក់ចំណាយផ្ទាល់ខ្លួនត្រូវបានបញ្ចូលទៅក្នុងប្រាក់ចំណាយផ្ទាល់ខ្លួនសម្រាប់ការព្យាបាលដោយពត់តម្រង់ធ្មេញទូលំទូលាយ ប្រសិនបើអ្នកជំងឺទទួលយកគម្រោងព្យាបាល។ **ការសង្គ្រោះបន្ទាន់ផ្នែកធ្មេញ៖** អ្នកផ្តល់សេវាដែលចូលរួមនឹងផ្តល់ការព្យាបាលសម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកធ្មេញក្នុងអំឡុងពេលម៉ោងធ្វើការ។ ក្រុមហ៊ុននឹងផ្តល់អត្ថប្រយោជន៍សម្រាប់សេវាដែលមានការធានារ៉ាប់រងដែលផ្តល់ដោយអ្នកផ្តល់សេវាដែលចូលរួមសម្រាប់ការព្យាបាលការសង្គ្រោះបន្ទាន់ផ្នែកធ្មេញ។ អ្នកចុះឈ្មោះអាចជួបព្យាបាលសម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកធ្មេញពីអ្នកផ្តល់សេវាដែលមិនចូលរួម ប្រសិនបើអ្នកចុះឈ្មោះរស់នៅឆ្ងាយជាង 50 ម៉ាយល៍ពីការិយាល័យអ្នកផ្តល់សេវាដែលចូលរួមណាមួយ។

# ធនធាន និងជំនួយគាំទ្រ

## សេវាបម្រើអតិថិជន

ទទួលបានជំនួយទាក់ទងនឹងការផ្លាស់ប្តូរផែនការ សំណួរអំពីធានារ៉ាប់រង, COBRA និងអ្វីៗជាច្រើនទៀត។

**1-877-606-6705**

**SEIU775BG-caregiver@magnacare.com**

(8 ព្រឹក ដល់ 6 ល្ងាច ថ្ងៃចន្ទ ដល់ សុក្រ)

## អត្ថប្រយោជន៍សុខភាព គណនីអនឡាញ

**myseiu.be/oe-online**

ចូលគណនី ឬបង្កើតគណនីដើម្បីធ្វើការផ្លាស់ប្តូរ និងចូលប្រើព័ត៌មានគម្រោង។

## វាក្យសព្ទធានារ៉ាប់រងសុខភាពទូទៅ

**myseiu.be/oe-terms**

ស្វែងយល់ពីនិយមន័យនៃវាក្យសព្ទទូទៅដើម្បីយល់កាន់តែច្បាស់អំពីការធានារ៉ាប់រងសុខភាពរបស់អ្នក។

| Kaiser Permanente of Washington | | |
|---|---|---|
| **សេវាបម្រើសមាជិក** | 1-888-901-4636 | myseiu.be/kp-member |
| **សេវាបម្រើសមាជិកថ្មី** | 1-888-844-4607 | myseiu.be/kp-new-member |
| **សេវាសុខភាពផ្លូវចិត្ត** | 1-888-287-2680 | myseiu.be/kaiser-bh |
| **ខ្សែទូរសព្ទជំនួយគិលានុបដ្ឋាក** | 1-800-297-6877 | myseiu.be/kp-nurse |
| **ជំនួយភាសាសម្រាប់សមាជិក** | 1-888-901-4636 | myseiu.be/kp-language |

| សុខភាពធ្មេញ | | |
|---|---|---|
| **Delta Dental** | 1-800-554-1907 | deltadentalwa.com |
| **Willamette Dental** | 1-855-433-6825 | myseiu.be/oe-willamette |

| អត្ថប្រយោជន៍ផ្សេងៗ | | |
|---|---|---|
| **EPIC Hearing** | 1-866-956-5400 | myseiu.be/epic |
| **Progyny (ការមានកូន និងការកសាងគ្រួសារ)** | 1-833-233-0517 | myseiu.be/progyny |

## ទទួលបានជំនួយគាំទ្រជាភាសារបស់អ្នក

**ហៅទូរសព្ទទៅសេវាបម្រើអតិថិជនតាមរយៈលេខ 1-877-606-6705 ឬអ៊ីមែលទៅកាន់ SEIU775BG-caregiver@magnacare.com។** អ្នកនឹងត្រូវបានភ្ជាប់ជាមួយអ្នកតំណាងដែលនិយាយភាសារបស់អ្នក ហើយអាចជួយឆ្លើយសំណួរអំពីការដាក់ពាក្យសុំ និងគ្រប់គ្រងអត្ថប្រយោជន៍របស់អ្នកបាន។

នៅពេលដែលអ្នកបានចុះឈ្មោះក្នុងការធានារ៉ាប់រងសុខភាព ជំនួយផ្នែកភាសានឹងមានផ្តល់ជូនតាមរយៈគម្រោងសុខភាពរបស់អ្នក។